នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០៣/០៧-០៩-២០០៩-អវតក/កសចស |
| ដាក់ទៅ | : | សហចៅក្រមស៊ើបអង្កេត |
| កាលបរិច្ឆេទឯកសារ | : | ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៣ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 11-Oct-2013, 14:22
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សម្ងាត់បំផុត**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ ក.ស.ច.ស: សម្ងាត់បំផុត/Strictly Confidential

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ: **ចូរទៅជាសាធារណៈ**

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍របស់សហមេធាវីចាត់តាំង

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញាអន្តរជាតិ:
លោក Nicholas KOUMJIAN

**ចម្លងជូន:**
លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**

ការិ.សហចៅក្រមស៊ើបអង្កេត:
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Mark B. HARMON

**ចម្លងជូន:**

អង្គភាពគាំពារការការពារក្ដី
Isaac ENDELEY

ជនសង្ស័យ
មាស មុត

សហមេធាវីចាត់តាំងសម្រាប់ជនសង្ស័យ
អាង ឧត្តម
Michael KARNAVAS

## I. សេចក្តីផ្តើម

១- សហព្រះរាជអាជ្ញាបម្រុងអន្តរជាតិ (“សហព្រះរាជអាជ្ញា”) ដាក់ការឆ្លើយតបនេះ ទៅនឹងចម្លើយតប (“ចម្លើយតបលើកទីពីរ”) ដែលបានដាក់ដោយលោក អាង ឧត្តម និងលោក Michael Karnavas (“សហមេធាវីចាត់តាំង”) នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣[1] តបទៅនឹង *សេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញា ស្តីពីទំនាស់ផលប្រយោជន៍របស់សហមេធាវីចាត់តាំង ទាក់ទិននឹងការតែងតាំងពីអតីតកាលរបស់ពួកគាត់ ដើម្បីធ្វើតំណាងឲ្យជនសង្ស័យ មាស មុត នៅក្នុងសំណុំរឿង ០០៣* (“សេចក្តីសន្និដ្ឋានបន្ថែម”)[2]។ ប្រវត្តិនីតិវិធីពេញលេញមានចែងនៅក្នុងកថាខណ្ឌ១ និងទី២ នៃសេចក្តីសន្និដ្ឋានបន្ថែម ហើយត្រូវបានបង្រួមតាមរយៈសេចក្តីយោង។ ការកំណត់កាលបរិច្ឆេទសម្រាប់ដាក់សារណាលើបញ្ហានេះត្រូវបានព្យួរដោយសហចៅក្រមស៊ើបអង្កេតកាលពីថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៣ ហើយបានបន្តនៅថ្ងៃទី២ ខែតុលា ឆ្នាំ២០១៣។ ការឆ្លើយតបនេះត្រូវបានដាក់ក្នុងរយៈពេលប្រាំថ្ងៃនៃថ្ងៃធ្វើការ ដូចបានកំណត់នៅក្នុង *ដីកាសម្រេចបន្តកាលបរិច្ឆេទសម្រាប់ការដាក់ឯកសារ ស្តីពីបញ្ហានៃអត្ថិភាពនៃទំនាស់ផលប្រយោជន៍ដូចបានចោទប្រកាន់នៅក្នុងការធ្វើតំណាងឲ្យ មាស មុត*[3]។

២- សម្រាប់គោលបំណងនៃការឆ្លើយតបនេះ សហព្រះរាជអាជ្ញាលើកអំពីការកំណត់ និងការអនុវត្តមិនត្រឹមត្រូវមួយចំនួននៃគោលការណ៍ច្បាប់ ដោយនៅរក្សា និងធ្វើការបញ្ជាក់បំភ្លឺចំពោះអំណះអំណាងដូចមានចែងកំណត់នៅក្នុងសំណើជាមូលដ្ឋាន[4]របស់ខ្លួន និងនៅក្នុងសេចក្តីសន្និដ្ឋានបន្ថែម។ ជាសរុបរួម សហព្រះរាជអាជ្ញានៅតែរក្សាគោលជំហរថា ការធ្វើតំណាងឲ្យ មាស មុត ដោយសហមេធាវីចាត់តាំងបង្កើតឲ្យមានទំនាស់ផលប្រយោជន៍ជាច្រើនដែលមិនអាច ឬមិនត្រូវបានគេលះបង់ចោលឲ្យបានត្រឹមត្រូវ។ សហព្រះរាជអាជ្ញាសូមស្នើឲ្យសហចៅក្រមស៊ើបអង្កេត កុំអះអាងទទួលយកការតែងតាំងសហមេធាវីចាត់តាំងនៅក្នុងសំណុំរឿង ០០៣ នេះ។

---

[1] **D56/9** សុំការអនុញ្ញាតបន្ថែមចំនួនទំព័រដែលបានកំណត់ និងសារណាឆ្លើយតបរបស់សហមេធាវីទៅនឹងសេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញា ស្តីពីទំនាស់ផលប្រយោជន៍របស់សហមេធាវីចាត់តាំង, ២៣ មេសា ២០១៣ (“ចម្លើយតបលើកទីពីរ”)។

[2] **D56/7** សេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីទំនាស់ផលប្រយោជន៍របស់សហមេធាវីចាត់តាំង, ៣ មេសា ២០១៣ (“សេចក្តីសន្និដ្ឋានបន្ថែម”)។

[3] **D56/14** *ដីកាសម្រេចបន្តកាលបរិច្ឆេទសម្រាប់ការដាក់ឯកសារ ស្តីពីបញ្ហានៃអត្ថិភាពនៃទំនាស់ផលប្រយោជន៍ដូចបានចោទប្រកាន់នៅក្នុងការធ្វើតំណាងឲ្យ មាស មុត*, ២ តុលា ២០១៣។

[4] **D56/1** សំណើសុំឲ្យច្រានចោលការតែងតាំងសហមេធាវីចាត់តាំង ផ្អែកលើមូលដ្ឋាននៃទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន, ២៤ ធ្នូ ២០១២ (“សំណើ”)។

## II. បញ្ហាបឋម

### *(i) ឯករាជ្យភាពនៃមុខងារ និងការធ្វើសេចក្តីសម្រេចចិត្តរបស់សហព្រះរាជអាជ្ញា*

៣- នៅក្នុងសេចក្តីផ្តើមនៃចម្លើយតប សហមេធាវីចាត់តាំង ចោទជាសំណួរអំពីលទ្ធភាពទាំងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងទាំងសហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងការបំពេញកិច្ចទាក់ទងនឹងវិវាទនេះ ដោយអវត្តមាននូវកិច្ចព្រមព្រៀមច្បាស់លាស់ពីដៃគូជាតិរបស់ខ្លួន[5] ដោយបន្ថែមនូវការអះអាងថា សហព្រះរាជអាជ្ញាអន្តរជាតិ "និងបុគ្គលិកអន្តរជាតិរបស់គាត់ កំពុងតែបំពេញកិច្ចដែលធ្វើឱ្យគ្មានន័យចំពោះគំនិតចូលរួម ឬការអនុម័តយល់ព្រមពីដៃគូជាតិរបស់គាត់"[6]។ ការចោទប្រកាន់ដូច្នេះគ្មានអង្គសេចក្តីទេ។ នៅក្នុងសេចក្តីសន្និដ្ឋានពីមុនរបស់ខ្លួន សហមេធាវីចាត់តាំងបានមើលឃើញថាជាការសមស្រប "ដើម្បីចោទជាសំណួរ"[7] ដោយសារការពិតថា "សហព្រះរាជអាជ្ញាជាតិ [...] មិនបានចុះហត្ថលេខាលើសំណើសុំដែលផ្ទុយទៅវិញគឺគ្រាន់តែដាក់ថាចម្លងជូន..."[8] ហើយនិងការនិយាយបង្កចថា សហព្រះរាជអាជ្ញាអន្តរជាតិ "មិនបានផ្តល់ការពន្យល់"[9]។ ដូចចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានសម្រេច គឺថាការធ្វើសេចក្តីសម្រេចចិត្តរបស់សហព្រះរាជអាជ្ញាគឺជាបញ្ហាដែលស្ថិតក្នុងវិសាលភាពទាំងស្រុងនៃឯករាជ្យភាពនៃមុខងាររបស់ខ្លួន។ សេចក្តីសម្រេចនេះមានសេចក្តីយ៉ាងដូច្នេះថា៖

> *បញ្ហាអំពីរបៀបធ្វើការងារជាមួយគ្នារបស់សហព្រះរាជអាជ្ញា តាមទស្សនៈរបស់យើង គឺជាបញ្ហាផ្ទៃក្នុងរបស់ការិយាល័យសហព្រះរាជអាជ្ញាឯករាជ្យ [...] អ្នកខាងក្រៅអាចរំពឹងថា សហព្រះរាជអាជ្ញាធ្វើការងារជាមួយគ្នា អាស្រ័យហេតុនេះអាចឱ្យគេសន្មតថា ពួកគាត់ដឹងពីសកម្មភាពរបស់គ្នាទៅវិញទៅមក។ បើសិនជាចាំបាច់ ពួកគាត់មានលទ្ធភាពបញ្ជាក់ឱ្យបានច្បាស់លាស់ និងជាផ្លូវការនូវការខ្វែងយោបល់គ្នាដោយមានជាសំណើសកម្មភាពផ្សេងៗ ឬត្រូវបានចាត់ឡើងដោយព្រះរាជអាជ្ញាម្ខាងទៀត*

---

[5] **D56/9** ចម្លើយតបលើកទីពីរ, កំណត់សំគាល់ខាងដើមលេខ១ ត្រង់ទំព័រ១។

[6] **D56/9** *ដដែលដូចខាងលើ,* ទំព័រទី១ កំណត់សំគាល់លេខ៥។

[7] **D56/4/1** សំណើសុំការអនុញ្ញាតបន្ថែមចំនួនទំព័រដែលបានកំណត់ និងសារណារបស់សហមេធាវី ស្តីពីទំនាស់ផលប្រយោជន៍នៅក្នុងការធ្វើតំណាងឱ្យលោក មាស មុត ក្នុងសំណុំរឿង ០០៣, ៤ មីនា ២០១៣ ត្រង់ទំព័រទី១ កំណត់សំគាល់លេខ៥ ("ចម្លើយតបលើកទីមួយ")។

[8] **D56/4/1** *ដដែលដូចខាងលើ*។

[9] **D56/4/1** *ដដែលដូចខាងលើ*។

[...]។ *ការណ៍នេះមិនមែនដើម្បីសហចៅក្រមស៊ើបអង្កេត ឬសម្រាប់បុគ្គលណាផ្សេងទៀត ដើម្បីចាប់យកតួនាទីគ្រប់គ្រងរបស់ការិយាល័យសហព្រះរាជអាជ្ញាឡើយ* [...][10]។

## III. ចម្លើយតបកំណត់ច្បាប់ជាធរមានមិនបានត្រឹមត្រូវ

*(i) បន្ទុកនៃភ័ស្តុតាង*

៤- បន្ទុកនៃការបង្ហាញភ័ស្តុតាងអំពីទំនាស់ផលប្រយោជន៍របស់មេធាវីការពារក្តី ស្ថិតនៅលើសហព្រះរាជអាជ្ញា[11]។ សហព្រះរាជអាជ្ញាសន្និដ្ឋាន ដូចមានមូលហេតុខាងក្រោម ថាបន្ទុកនេះត្រូវបានបំពេញយ៉ាងពេញលេញអស់ហើយ។

*(ii) បទដ្ឋាននៃភ័ស្តុតាង*

៥- ក្នុងចម្លើយតបរបស់ខ្លួន សហមេធាវីចាត់តាំងមិនជំទាស់ថា បទដ្ឋានសម្រាប់កំណត់ថាតើ ទំនាស់ផលប្រយោជន៍មានអត្ថិភាពឬអាចកើតមានឬអត់ ជាបទដ្ឋានសត្យានុម័ត មិនមែនជាការកំណត់អត្តនោម័តសម្រាប់សាម៉ីមេធាវីនោះទេ។ ពួកគាត់មិនបានជំទាស់ទៅនឹងប្រភពច្បាប់យោងដែលបានលើកយោងដោយសហព្រះរាជអាជ្ញានៅត្រង់កថាខណ្ឌទី២៦ ដល់២៨ នៃសេចក្តីសន្និដ្ឋានបន្ថែមទេ ដែលបង្ហាញឱ្យឃើញថា ការធ្វើតេស្តផ្នែកច្បាប់ជាធរមានមានន័យថា "*ភាពអាចព្យាករបានសមហេតុផល*"[12]។ សហមេធាវីចាត់តាំងទទួលស្គាល់បន្ថែមទៀតថា "ទំនាស់ផលប្រយោជន៍នឹងកើតឡើង បើសិនជាមាន "ហានិភ័យជាដុំកំភួន" ដែលថាការធ្វើតំណាងឱ្យកូនក្តីអតីតកាល នឹងធ្វើឱ្យកូនក្តីបច្ចុប្បន្នទទួលរងផលប៉ះពាល់ផ្ទុយគ្នា"[13]។

---

[10] **D20/4/4** សេចក្តីពិចារណាររបស់អង្គបុរេជំនុំជម្រះទាក់ទិននឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ជំទាស់នឹងសេចក្តីសម្រេចស្តីពីសំណើសុំពន្យាពេលកំណត់ នឹងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងសំណុំរឿង ០០៣ (មតិរបស់ចៅក្រម Lahuis និងចៅក្រម Downing), ២ វិច្ឆិកា ២០១១ ត្រង់កថាខណ្ឌទី៨ [សង្កត់ន័យដោយអក្សរទ្រេត]។

[11] **D56/9** ចម្លើយតបលើកទីពីរ, កំណត់សំគាល់ខាងដើមលេខ១ ត្រង់ទំព័រ១៥។

[12] **D56/9** ចម្លើយតបលើកទីពីរ, កំណត់សំគាល់ខាងដើមលេខ១ ត្រង់ទំព័រ៩។

[13] **D56/9** *ដដែលដូចខាងលើ,* ត្រង់កថាខណ្ឌទី២០។

៦- ប៉ុន្តែចម្លើយតបអនុវត្តនូវការធ្វើតេស្តសាកល្បងតាមបែបអត្តនោម័ត ដោយកំពុងតែតវ៉ាថាទំនាស់ផលប្រយោជន៍នឹងមិនកើតមានឡើងឡើយឲ្យតែខ្លួនគេបានពិចារណាថា បុគ្គលខ្លួនឯងពេញចិត្តថា ទំនាស់នោះពិតជាមិនមាន និងការអះអាងជាបុគ្គលថា ទំនាស់នោះពិតជានឹងមិនកើតមាន។ ជាឧទាហរណ៍ត្រង់កថាខណ្ឌទី១៧ ចម្លើយតបសរសេរថា៖

*ទោះក្នុងព្រឹត្តិការណ៍ណាក៏ដោយ សហមេធាវីមានមូលដ្ឋានហួសពីសុចរិតភាពដើម្បីអះអាងថា គ្មានចំណេះដឹងណាដែលទទួលបានពីលោក អៀង សារី នឹងត្រូវយកទៅប្រើជាជំនួយដល់លោក មាស មុត ដើម្បីធ្វើឲ្យខូចដល់ផលប្រយោជន៍របស់លោក អៀង សារី ឡើយ។ ស្រដៀងគ្នានេះ សហមេធាវីមានមូលដ្ឋានហួសពីសុចរិតភាពដើម្បីអះអាងថា គ្មានចំណេះដឹងណាដែលទទួលបានពីលោក មាស មុត នឹងត្រូវយកទៅប្រើដើម្បីការពារលោក អៀង សារី ដើម្បីធ្វើឲ្យខូចដល់ផលប្រយោជន៍របស់លោក មាស មុត ឡើយ។ ការធ្វើតំណាងនេះ គឺផ្អែកលើទ្រឹស្តីនៃករណីនិមួយៗ ដែលនៅគ្រប់ករណីទាំងនេះ គឺទាំងលោក អៀង សារី និងទាំងលោក មាស មុត ជាអ្នកដែលនាំសហមេធាវីលើចំណាត់ការ បន្ទាប់ពីមានការពិគ្រោះយោបល់ ការប្រឹក្សា និងពិភាក្សាយ៉ាងប្រុងប្រយ័ត្ន។*

៧- សហមេធាវីចាត់តាំងហាក់ដូចជាឈានមុខនៅក្នុងការយល់ឃើញថា ទំនាស់ផលប្រយោជន៍គឺវាមានលក្ខណៈជាក់លាក់តាមករណីនិមួយៗ និងមានលក្ខណៈតូចតាច ដែលគ្មានន័យអ្វី ឬ អាចឲ្យគេកំណត់បាន[14] នូវ "តំបន់គ្រោះថ្នាក់"[15]។ ដូចមានចែងកំណត់ក្នុងសេចក្តីសន្និដ្ឋានបន្ថែម បទដ្ឋាន និងក្រមសីលធម៌វិជ្ជាជីវៈដែលមាននៅទូទាំងដែនយុត្តាធិការជាច្រើនបញ្ជាក់អះអាងថា ទំនាស់ផលប្រយោជន៍នឹងកើតមានឡើងក្នុងស្ថានភាពយ៉ាងហោចណាស់ប្រាំ ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០៣៖

(ក) បើសិនជាគេអាចព្យាករបានដោយសមហេតុផលថា ផលប្រយោជន៍របស់កូនក្តីពីរនាក់ អាចនឹងមានភាពផ្ទុយគ្នាយ៉ាងជាក់ស្តែងនៅក្នុងកិច្ចដំណើរការនីតិវិធីដ៏សំខាន់ដែលពាក់ព័ន្ធ។

(ខ) បើសិនជាគេអាចព្យាករបានដោយសមហេតុផលថា ព័ត៌មានសម្ងាត់ពាក់ព័ន្ធនឹងកូនក្តីចាស់ មានសារសំខាន់ជាក់ស្តែងសម្រាប់កូនក្តីបច្ចុប្បន្ន ប៉ុន្តែពុំមានអត្ថប្រយោជន៍ដល់កូនក្តីចាស់។

---

[14] សូមមើល **D56/7** សេចក្តីសន្និដ្ឋានបន្ថែម, កំណត់សំគាល់ខាងដើមលេខ២ ត្រង់ទំព័រ១៣ ដោយលើកយោងរឿងក្តី *Goldstein ទល់នឹង Lees* (1975) 46 Cal.App.3d 614, 620។

[15] សូមមើល ឧ. **D56/9** ចម្លើយតបលើកទីពីរ, កំណត់សំគាល់ខាងដើមលេខ១ ត្រង់ទំព័រ១៧ និង២០។

(គ) បើសិនជាគេអាចព្យាករបានដោយសមហេតុផលថា ចំណេះដឹងដែលទទួលបានពីកូនក្តីចាស់ អាចនឹងមានអត្ថប្រយោជន៍ដល់ផលប្រយោជន៍កូនក្តីបច្ចុប្បន្ន។

(ឃ) បើសិនជាគេអាចព្យាករបានដោយសមហេតុផលថា ព័ត៌មានសម្ងាត់មានសារសំខាន់ជាក់ស្តែងចំពោះមេធាវីរបស់កូនក្តីបច្ចុប្បន្ន ហើយផលប្រយោជន៍របស់កូនក្តីទាំងពីរ មានភាពផ្ទុយគ្នាយ៉ាងជាក់ស្តែង។ ហើយនិង

(ង) បើសិនជាមានហានិភ័យជាដុំកំភួនដែលការធ្វើតំណាងឲ្យកូនក្តីបច្ចុប្បន្ន នឹងដាក់កម្រិតយ៉ាងជាក់ស្តែងដោយសារកាតព្វកិច្ចកំពុងបន្តរបស់មេធាវីទៅលើកូនក្តីចាស់[16]។

*(iii) ភាពគ្រប់គ្រាន់នៃ* ភស្តុតាងដែលមានតម្លៃពាក់ព័ន្ធ *នៃទំនាក់ទំនងរវាងថ្នាក់លើ-ថ្នាក់ក្រោម គឺជាលក្ខណតម្រូវសម្រាប់កំណត់អំពីទំនាស់ផលប្រយោជន៍*

៨- សហព្រះរាជអាជ្ញានៅប្រកាន់ជំហរទោះបីជាថា ទំនាស់ផលប្រយោជន៍ "អាចព្យាករបានដោយសមហេតុផល" មិនតម្រូវឲ្យមានភស្តុតាងសន្និដ្ឋានជាចុងក្រោយក្តី ប៉ុន្តែផ្ទុយទៅវិញ វាជាការពិនិត្យទៅលើ *ភស្តុតាងដែលមានតម្លៃជាប់ពាក់ព័ន្ធ*។ បទដ្ឋាននៃ*ភស្តុតាងមានតម្លៃជាប់ពាក់ព័ន្ធ* អនុវត្តស្មើគ្នាចំពោះភាពជិតស្និទ្ធនៃទំនាក់ទំនងថ្នាក់លើ-ថ្នាក់ក្រោមបង្គាប់រវាងកូនក្តីពីរនាក់ដែលទំនងជានឹងបង្កើតឲ្យមានទំនាស់ផលប្រយោជន៍។ ក្នុងរឿងក្តី *Jadranko Prlić*[17] អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានសម្រេចថា "ទំនាស់ផលប្រយោជន៍ទំនងជានឹងកើតឡើងរវាងជនជាប់ចោទពីរនាក់ បើសិនជាមិនទាន់កើតមាន" ដោយសារការពិត "ជនជាប់ចោទទាំងពីរត្រូវបានចោទប្រកាន់ចំពោះអំពើព្រហ្មទណ្ឌដូចគ្នាហើយត្រូវបានភ្ជាប់ទៅនឹងទំនាក់ទំនងជិតស្និទ្ធប្រហាក់ប្រហែលគ្នា រវាងថ្នាក់លើ-ថ្នាក់ក្រោមនៅក្នុងរយៈពេលដែលពាក់ព័ន្ធ"[18]។ ក្នុងករណីនេះ ចុងចោទម្នាក់ (Ivica Rajić) បានប្រឈមមុខនឹង

---

[16] **D56/7** សេចក្តីសន្និដ្ឋានបន្ថែម, កំណត់សំគាល់ខាងជើមលេខ២ ត្រង់ទំព័រ២២។

[17] *រដ្ឋអាជ្ញា ទល់នឹង Jadranko Prlić និងគូកន.*, សំណុំរឿងលេខៈ IT-04-74-PT, សេចក្តីសម្រេចលើសំណើសុំការតែងតាំងមេធាវីការពារក្តី (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ៣០ កក្កដា ២០០៤ ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Prlič*")។

[18] *ដដែលដូចខាងលើ,* កថាខណ្ឌទី២៩។

បទចោទទៅតាមទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ ដោយផ្អែកលើការបញ្ជា និងការត្រួតត្រារបស់គាត់ទៅលើអង្គភាពក្រុមប្រឹក្សាការពារប្រទេសក្រូអាតជាច្រើន។ ចុងចោទដទៃទៀត (Bruno Stojić) ត្រូវបានចោទប្រកាន់ថាជាប្រធានមន្ទីរការពារ HVO (ក្រោយមកជាក្រសួង) ការពារប្រទេស ទាក់ទិនទៅនឹងអំពើព្រហ្មទណ្ឌដូចគ្នា[19]។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ទំនាក់ទំនងជិតស្និទ្ធរវាងថ្នាក់លើ-ថ្នាក់ក្រោម ត្រូវបានកំណត់រវាងជនជាប់ចោទទាំងពីរនាក់ ទោះបីជាការសន្និដ្ឋានរបស់មេធាវីការពារក្ដីថា គ្មានចំណុចណាមួយនៃការទាក់ទងគ្នារវាងពួកគេបានកើតឡើង[20] ដោយសារមុខតំណែងនៅក្នុងឋានានុក្រមរបស់ពួកគេរៀងៗខ្លួនក៏ដោយ មានន័យថា Rajić ត្រូវបានចោទប្រកាន់ក្នុងនាមជាយោធា ជាមេបញ្ជាការកងទ័ព ចំណែកឯ Stojić ត្រូវបានចោទប្រកាន់ក្នុងនាមជាអាជ្ញាធរស៊ីវិល[21]។ អង្គជំនុំជម្រះសាលាដំបូង បានច្រានចោលសារណាសន្និដ្ឋានរបស់មេធាវីនេះ ដោយផ្ដល់សំអាងហេតុថា "ការពិតដោយគ្រាន់តែជនជាប់ចោទម្នាក់ ត្រូវបានចោទប្រកាន់ក្នុងនាមជាអាជ្ញាធរស៊ីវិល ឯម្នាក់ទៀតជាអាជ្ញាធរយោធា មិនបានច្រានចោលអត្ថិភាពនៃទំនាក់ទំនងថ្នាក់លើ-ថ្នាក់ក្រោមរវាងពួកគេឡើយ"[22]។

៩- អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY មួយផ្សេងទៀត បានអនុម័តយកសំអាងហេតុស្រដៀងគ្នានេះនៅក្នុងរឿងក្ដី *Rasim Delić*[23]។ នៅទីនេះ អង្គជំនុំជម្រះសាលាដំបូងយល់ស្របជាមួយអ្នកកាន់កាប់បញ្ជីថា គេមាន "លទ្ធភាពពិតប្រាកដ" ថាមេធាវីការពារក្ដីជនជាប់ចោទនៅក្នុងសំណុំរឿងពីរដាច់ពីគ្នាអាចក្លាយជា "ប្រឆាំងគ្នា" បើសិនជាចោទថា ជនជាប់ចោទម្នាក់គឺជាអ្នកក្រោមបង្គាប់ផ្ទាល់របស់ជនជាប់ចោទម្នាក់ផ្សេងទៀត[24]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា ការពិតដែលជនជាប់ចោទទាំងពីរត្រូវបានចោទប្រកាន់ចំពោះ "អំពើព្រហ្មទណ្ឌដូចគ្នា" ហើយត្រូវបានភ្ជាប់ទៅនឹងទំនាក់ទំនងជិតស្និទ្ធប្រហាក់ប្រហែលគ្នារវាងថ្នាក់លើ-ថ្នាក់ក្រោម នៅក្នុងរយៈពេលដែលពាក់ព័ន្ធ" បានផ្ដល់

---

[19] *ដដែលដូចខាងលើ,* កថាខណ្ឌទី១៨-១៩។

[20] *ដដែលដូចខាងលើ,* កថាខណ្ឌទី២០។

[21] *ដដែលដូចខាងលើ,* កថាខណ្ឌទី២០។

[22] *ដដែលដូចខាងលើ,* កថាខណ្ឌទី២៩។

[23] *រដ្ឋអាជ្ញា ទល់នឹង Rasim Delić*, សំណុំរឿងលេខ: IT-04-83-PT, សេចក្ដីសម្រេចលើញត្តិស្នើសុំឱ្យពិនិត្យលើសេចក្ដីសម្រេចរបស់អ្នកកាន់កាប់បញ្ជីដែលនិយាយថា លោក Stéphane Bourgon មិនអាចត្រូវបានតែងតាំងឱ្យធ្វើជាតំណាងរបស់ Rasim Delić បាននោះ (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ១០ ឧសភា ២០០៥។

[24] *ដដែលដូចខាងលើ*។

នូវមូលហេតុសម្រាប់ឲ្យអ្នកកាន់កាប់បញ្ជីធ្វើការសន្និដ្ឋានជាចុងក្រោយ "ថា ទំនាស់ផលប្រយោជន៍ [គឺជា] *លទ្ធភាព* មួយនៅក្នុងករណីនេះ" ហើយនិងមិនអនុញ្ញាតឲ្យមានការធ្វើតំណាងទ្វេរ[25]។

១០- ដោយយកតាមរឿងក្តី *Jadranko Prlić* និង *Rasim Delić* គឺនៅពេលដែលអង្គហេតុនានានៅក្នុងការចោទប្រកាន់នាំទៅដល់ការបង្ហាញឲ្យឃើញនូវភាពជាប់ពាក់ព័ន្ធនៃ ទំនាក់ទំនងជិតស្និទ្ធរវាងថ្នាក់លើ និងថ្នាក់ក្រោម ការណ៍នេះគឺវាលើសពីភាពគ្រប់គ្រាន់នៅក្នុងការគាំទ្រការសម្រេចមួយដែលថា ផលប្រយោជន៍របស់ជនជាប់ចោទនៅក្នុងសំណុំរឿងមួយ ឬច្រើន អាចក្លាយទៅជាមានភាពផ្ទុយគ្នាយ៉ាងជាក់ស្តែងដែលបង្កើតឲ្យមានទំនាស់ផលប្រយោជន៍ ដែលធ្វើឲ្យការធ្វើតំណាងទ្វេរមិនអាចត្រូវបានអនុញ្ញាត។

*(iv) ភាពទាក់ទងគ្នានៃទ្រឹស្តីមេធាវីការពារក្តីនៅក្នុងការវាយតម្លៃលើ ទំនាស់ផលប្រយោជន៍*

១១- សហមេធាវីចាត់តាំងបានដាក់ជូនថា ពួកគាត់ឯកភាពថាមិនមានទំនាស់ផលប្រយោជន៍ណាមួយរវាង អៀង សារី និង មាស មុត កំពុងមានអត្ថិភាព ឬអាចនឹងកើតឡើងនោះទេ[26]។ ចម្លើយតបនេះ លើកឡើងថា មិនមានហានិភ័យបែបដូច្នេះណាមួយកំពុងមានអត្ថិភាព *"ដោយមានមូលដ្ឋាននៅលើទ្រឹស្តី នៃរឿងក្តីរៀងៗខ្លួន* ដែលនៅក្រោមទ្រឹស្តីនោះ ទាំងលោក អៀង សារី និងទាំង មាស មុត ធ្លាប់បានណែនាំឲ្យសហមេធាវីការពារក្តីបន្តកិច្ចការទៅទៀត បន្ទាប់ពីមានការផ្តល់ប្រឹក្សាមានការផ្តល់យោបល់ និងមានការសម្រេច ដោយប្រុងប្រយ័ត្ន"។ ក្នុងរឿងនេះ ចម្លើយតបគឺមានលក្ខណៈប្រញាប់ប្រញាល់ពេក និងពុំមានបង្ហាញអំពីការពិចារណាដ៏មានអត្ថន័យ ណាមួយលើលទ្ធភាពនៃការវិវត្តន៍ខ្សែបន្ទាត់របស់មេធាវីការពារក្តីនៅក្នុងដំណើរការប្រព្រឹត្តទៅនៃកិច្ចស៊ើបសួរ ជាពិសេសគឺកិច្ចស៊ើបសួរមួយដែលឋិតនៅក្នុងដំណាក់កាលដំបូងនៅឡើយ។ នៅក្នុង រឿងក្តី *Jadranko Prlić* អង្គជំនុំជម្រះ សាលាដំបូងបានទទួលយកថា ទ្រឹស្តី ឬ យុត្តិសាស្ត្រជាក់ស្តែង ឬដែលអាចមាន របស់មេធាវីការពារក្តី គឺពុំមែនមិនផ្លាស់ប្តូរនោះទេ ហើយជារឿយៗ វាតែងតែមានការវិវត្តន៍នៅក្នុងអំឡុងពេលនៃ ដំណើរការប្រព្រឹត្តទៅនៃកិច្ចដំណើរការនីតិវិធី៖

---

[25] *ដដែលដូចខាងលើ* [សង្កត់ន័យត្រង់អក្សរទ្រេត]។

[26] **D56/9** ចម្លើយតបលើកទីពីរ, កំណត់សម្គាល់*ខាងលើ* លេខ១ ត្រង់កថាខណ្ឌ ៥៣។

*ចុងបញ្ចប់ អង្គហេតុតែមួយគត់ប៉ុណ្ណោះដែល ទាំងជនជាប់ចោទមានបំណងជជែកការពារភាពស្លូតត្រង់ទាំងស្រុងរបស់ពួកខ្លួននោះ គឺខ្លួនឯងវាជា ការធានាមួយប្រឆាំងនឹងទំនាស់ផលប្រយោជន៍។ ភាពស្លូតត្រង់អាចត្រូវបានជជែកការពារតាមរបៀបជាច្រើនយ៉ាង ហើយជាញឹកញាប់ ខ្សែបន្ទាត់របស់មេធាវីការពារក្តីអាចនឹងមានការវិវត្តន៍នៅក្នុងដំណើរការនៃរឿងក្តី។ វាជាករណីយកិច្ចរបស់ក្រុមមេធាវីការពារក្តីក្នុងការយកកត្តានេះមកពិចារណា នៅពេលធ្វើការវាយតម្លៃលើទំនាស់ផលប្រយោជន៍ជាសក្តានុពល*[27]។

១២- ស្រដៀងគ្នានេះដែរ នៅត្រង់កថាខណ្ឌទី២២ នៃចម្លើយតប សហមេធាវីចាត់តាំងបានអះអាងថា "ការតំណាងរបស់ពួកគេចំពោះលោក មាស មុត នឹងមិននាំឲ្យពួកគេទទួលយកនូវទ្រឹស្តី ឬយុត្តិសាស្ត្រផ្សេងៗពីអ្វីដែលពួកគេនឹងយកមកអនុវត្ត នោះទេ ប្រសិនបើពួកគេមិនបានធ្វើតំណាងឲ្យលោក អៀង សារី"[28]។ ការអះអាងនេះ គឺមិនទាក់ទងនឹងការកំណត់ពីទំនាស់ផលប្រយោជន៍ដ៏សមហេតុសមផល ឬដែលអាចប្រមើលមើលជាមុនបាន ដោយសារកាតព្វកិច្ចដែលកំពុងមានទំនាស់ ស្តីពីការរក្សាការសម្ងាត់ ឬភាពស្មោះត្រង់ចំពោះ អៀង សារី និងភាពស្មោះត្រង់ចំពោះ មាស មុត នោះទេ។ បញ្ហាស្នូល គឺមិនមែននៅលើថាតើទ្រឹស្តី ឬយុត្តិសាស្ត្រទាំងនោះរបស់ក្រុមមេធាវីការពារក្តី មានភាពខុសគ្នាដែរឬទេ បើវាមិនមែនសម្រាប់ការដាក់បង្ហាញពីមុននោះ នោះឡើយ។ បញ្ហាស្នូលគឺ ថាតើគេអាចប្រមើលមើលបានយ៉ាងសមហេតុសមផលដែរឬទេ ចំពោះអ្នកធ្វើសេចក្តីសម្រេចសត្យានុម័តម្នាក់ ដែលកំពុងបន្តបំពេញករណីយកិច្ចស្តីពីការរក្សាការ សម្ងាត់ និង ភាពស្មោះត្រង់ជូនចំពោះកូនក្តីដែលបានទទួលមរណភាពណាម្នាក់ - គឺជាករណីយកិច្ច ទាំងឡាយដែលសហមេធាវីចាត់តាំងមិនបានជជែកតវ៉ា[29] - ដែលអាចនឹងមានការកម្រិតនូវសិទ្ធិ របស់កូនក្តីថ្មី ទៅនឹង "ភាពស្មោះត្រង់ដែលមិនអាចបែងចែកបាន"[30] របស់ក្រុមមេធាវីការពារក្តី ដើម្បី "ស្វែងរកផលប្រយោជន៍របស់កូនក្តីខ្លួន ដោយមិនមានការកម្រិតណាមួយឡើយ"[31] ឲ្យតែ

[27] *ដដែលដូចមុន* ត្រង់កថាខណ្ឌ ២៩។

[28] **D56/9** ចម្លើយតបលើកទីពីរ, កំណត់សម្គាល់*ខាងលើ* លេខ១ ត្រង់កថាខណ្ឌ ២២។

[29] **D56/9** *ដដែលដូចមុន,* ត្រង់កថាខណ្ឌ ៤-៧។

[30] **D56/7** សេចក្តីសន្និដ្ឋានបន្ថែម, កំណត់សម្គាល់*ខាងលើ* លេខ២ ត្រង់កថាខណ្ឌ ១៣, ដោយបានលើករឿងក្តី *Goldstein v. Lees* (ឆ្នាំ១៩៧៥) 46 Cal.App.3d 614, 620។

[31] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី *Prlić*, កំណត់សម្គាល់*ខាងលើ* លេខ២៤ ត្រង់កថាខណ្ឌ ២៩។

ករណីយកិច្ច របស់ពួកគាត់ធ្វើឡើងដើម្បីលើកស្ទួយដល់ផលប្រយោជន៍របស់អតីតកូនក្តីរបស់ពួកគាត់។ សហព្រះរាជអាជ្ញា ធ្លាប់បានធ្វើរួចហើយនូវការបង្ហាញជាក់ស្តែងមួយ អំពីថាតើទំនាស់មួយបែបដូច្នេះ ទំនងជាសមហេតុសមផលខ្លាំងណាស់ នៅពេលវាកើតឡើងនៅក្នុងដំណើរការនៃកិច្ចស៊ើបសួរបាន ដោយរបៀបណានោះ[32]។

១៣- សហព្រះរាជអាជ្ញា សូមជូនសេចក្តីសន្និដ្ឋានបន្ថែមទៀតថា នៅលើមូលដ្ឋាននៃការចោទប្រកាន់ជាអង្គហេតុពិតជាក់ស្តែងដែលបានលើកឡើងនៅត្រង់កថាខណ្ឌទី ២៤-៣៤ ខាងក្រោម ដែលថាភាពថិតនៅកៀកជិតគ្នារវាងថ្នាក់លើ-ថ្នាក់ក្រោម អៀង សារី និង មាស មុត គឺ កៀកគ្នាដូចជា ឬកៀកគ្នាជិតជាង ការដែលសហជនជាប់ចោទថ្នាក់លើ-ថ្នាក់ក្រោម នៅក្នុងរឿងក្តី *Jadranko Prlić* ថិតនៅកៀកជិតគ្នាទៅទៀត ដែលអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានទទួលយកថា ក្រុមមេធាវីកាពារក្តីគឺថិតនៅក្នុងគោលជំហរមួយដែល "មិនមានលទ្ធភាពការពារផលប្រយោជន៍កូនក្តីរបស់ខ្លួនឲ្យបានល្អបំផុត ដែលប្រកបទៅដោយការព្យាយាម និងឲ្យបានទាន់ពេលដូចដែលគេបានរំពឹង និងតម្រូវឲ្យក្រុមមេធាវីការពារក្តីធ្វើដូច្នោះ នោះទេ៖ គឺដើម្បីបន្ទន់ឥរិយាបថជាជាងដើម្បីស្វែងរកផលប្រយោជន៍របស់កូនក្តីខ្លួន ដោយមិនមានការកម្រិតណាមួយឡើយ"[33]។ ខណៈដែល អៀង សារី និង មាស មុត មិនមែនជាសហជនជាប់ចោទនៅក្នុងកិច្ចដំណើរការនីតិវិធីតែមួយដូចគ្នានោះ ទំនាក់ទំនងនៃភាពថិតនៅកៀកជិតគ្នារវាងថ្នាក់លើ-ថ្នាក់ក្រោម របស់ពួកគេបែបដូច្នេះនោះ គឺផលប្រយោជន៍របស់ពួកគាត់ដែលអាចប្រមើលមើលជាមុនបានយ៉ាងសមហេតុសមផលនោះ វាគឺជា ឬនឹងក្លាយទៅជាមាន ការប្រឆាំងនឹងគ្នា នៅក្នុងកិច្ចដំណើរការនីតិវិធីដែលកំពុងបន្តធ្វើណាមួយដែលប្រឆាំងនឹង មាស មុត។ សហមេធាវីចាត់តាំង មិនបានជជែកតវ៉ាអំពីករណីយកិច្ចស្តីពីភាពស្មោះត្រង់ ដែលកំពុងបន្តបំពេញជូន អៀង សារី នោះទេ[34]។ នៅក្នុងកាលៈទេសៈទាំងនេះ សហព្រះរាជអាជ្ញាអន្តរជាតិ សូមជូនសេចក្តីសន្និដ្ឋានថា យ៉ាងហោចណាស់ហានិភ័យនៃទំនាស់ផលប្រយោជន៍គឺ អាចប្រមើលមើលបានយ៉ាងសមហេតុសមផល បានដែរ។

### *(v) ភាពត្រឹមត្រូវនៃចម្លើយតបពាក់ព័ន្ធនឹងការអនុវត្តរបស់តុលាការ ICTY នៅក្នុងការចាត់តាំងក្រុមមេធាវីការពារក្តី*

[32] សូមអាន **D56/7** សេចក្តីសន្និដ្ឋានបន្ថែម, កំណត់សម្គាល់*ខាងលើ* លេខ២ ត្រង់កថាខណ្ឌ ៥៧-៦៤។

[33] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី *Prlić*, កំណត់សម្គាល់*ខាងលើ* លេខ២៤ ត្រង់កថាខណ្ឌ ២៩។

[34] **D56/9** ចម្លើយតបលើកទីពីរ, កំណត់សម្គាល់*ខាងលើ* លេខ១ ត្រង់កថាខណ្ឌ ១៦។

១៤- នៅក្នុងចម្លើយតប សហមេធាវីចាត់តាំងបានដាក់ជូនថា ក្រុមមេធាវីការពារក្តី ត្រូវបានចាត់តាំងនៅក្នុងរឿងក្តីជាច្រើន ដូចជា រឿងក្តី Srebrenica នៅតុលាការ ICTY ជាដើម ដែលកូនក្តីពីអតីត និងបច្ចុប្បន្នរបស់គាត់ ត្រូវបានចោទប្រកាន់ថាបានពាក់ព័ន្ធនឹងព្រឹត្តិការណ៍តែមួយដូចគ្នា[35] ដើម្បីគាំទ្រដល់សេចក្តីអះអាងដែលថាការអនុវត្តពីមុននៅតុលាការ ICTY (និងនៅ អវតក) ស្នើឡើងថាក្រុមមេធាវីការពារក្តីអាចធ្វើជាតំណាងបានយ៉ាងសមស្របឱ្យដល់ពួកអតីតថ្នាក់លើ និងថ្នាក់ក្រោមមួយចំនួននៅពាសពេញរឿងក្តីដែលខុសៗគ្នា។ សេចក្តីអះអាងនេះ មិនបានធ្វើឱ្យបទដ្ឋានជាសត្យានុម័តនៃសក្ខីកម្មដែលកំពុងឋិតនៅជាធរមាន នៅក្នុងការវាយតម្លៃលើទំនាស់ផលប្រយោជន៍នោះ ថយចុះទេ។ សហមេធាវីចាត់តាំង គ្រាន់តែបានរៀបរាប់ - ដែលប្រកបទៅដោយកំហុសយ៉ាងធ្ងន់ធ្ងរ- អំពីស្ថានភាពនៃក្រុមមេធាវីការពារក្តី នៅក្នុងរឿងក្តីដោយឡែកនីមួយៗ ប៉ុណ្ណោះ ។

១៥- ជាឧទាហរណ៍ សហមេធាវីចាត់តាំង បានអះអាងនៅក្នុងកិច្ចដំណើរការនីតិវិធី នៅតុលាការ ICTY ថា Nenad Petrušić បានបម្រើក្នុងឋានៈជាមេធាវីការពារក្តីនាំមុខឱ្យឧត្តមសេនីយ៍ Krstić ដែលនៅក្រោមបញ្ជាទូទៅរបស់ឧត្តមសេនីយ៍ Mladić។ នៅពេលនោះ លោក Petrušić បានអះអាងថាបានក្លាយទៅជាសហមេធាវីការពារក្តីឱ្យឧត្តមសេនីយ៍ Miletić ដែលជាអ្នកនៅក្រោមបង្គាប់ម្នាក់ផ្សេងទៀតរបស់ឧត្តមសេនីយ៍ Mladić។ លើសពីនេះ ពួកគាត់បានថ្លែងថា បច្ចុប្បន្ននេះ លោក Petrušić គឺជាសមាជិកសំខាន់មួយរូបក្នុងចំណោមសមាជិកច្បាប់នានា របស់ឧត្តមសេនីយ៍ Mladić[36]។ មិនមានប្រភព ឬច្បាប់ជាក់លាក់ណាមួយ ត្រូវបានផ្តល់ដោយសហមេធាវីចាត់តាំងដើម្បីគាំទ្រដល់ការបញ្ជាក់អះអាងនេះឡើយ។ តាមអង្គហេតុពិត លោក Petrušić មិនត្រូវបានចាត់តាំងឱ្យធ្វើជាសហមេធាវីឱ្យឧត្តមសេនីយ៍ Miletić នោះឡើយ[37]។ សេចក្តីសម្រេចរបស់អ្នកកាន់កាប់បញ្ជី ICTY បានគាំទ្រដល់ការពិនិត្យឡើងវិញនៅ ចំពោះមុខអង្គជំនុំជម្រះសាលាដំបូងទីII[38] ដោយមិនបានទទួលយកនូវការតំណាងរបស់លោក Petrušić ឱ្យឧត្តមសេនីយ៍ Miletić នៅលើទឡ្ហីករណ៍ស្តីពីទំនាស់ផលប្រយោជន៍ ដោយមកពីការ តំណាងពីមុនរបស់គាត់ឱ្យឧត្តមសេនីយ៍

[35] **D56/9** *ដដែលដូចមុន,* ត្រង់កថាខណ្ឌ ៨។

[36] **D56/9** *ដដែលដូចមុន,* ត្រង់កថាខណ្ឌ ៣៧។

[37] *រដ្ឋអាជ្ញា ទល់នឹង Tolimir និងគូកន,* សេចក្តីសម្រេចស្តីពីការចាត់តាំងសហមេធាវីការពារក្តីឱ្យ Radivoje Miletić, សំណុំរឿងលេខ IT-05-88-PT, ២៨ កញ្ញា ២០០៥។

[38] *ដដែលដូចមុន,* ត្រង់កថាខណ្ឌ ៣៨។

Krstić ហើយហេតុដូច្នោះ គឺវាផ្ទុយទៅនឹងផលប្រយោជន៍នៃយុត្តិធម៌[39]។ លើសពីនេះ ដូចដែលសហមេធាវីចាត់តាំងបានទទួលស្គាល់នៅត្រង់កំណត់សម្គាល់ជើងទំព័រ ៣៩ នៅក្នុងចម្លើយតបរបស់ពួកគាត់ដូច្នោះដែរថាលោក Petrušić គឺមិនត្រូវបានចាត់តាំងឱ្យធ្វើជាមេធាវីឬជាសហមេធាវីការពារក្តីឱ្យឧត្តមសេនីយ៍ Mladić នោះឡើយ។

១៦- សហមេធាវីចាត់តាំងបានអះអាងបន្ថែមទៀតថាការចូលរួមចំណែករបស់លោក Andrew Cayley QC ដែលជាអតីតសហព្រះរាជអាជ្ញាអន្តរជាតិ ជាមួយនឹងលោក Gregory Kehoe និងលោក Payam Akhavan ដូចជាក្រុមមេធាវីការពារក្តីនៅក្នុងរឿងក្តី *Gotovina* ដូច្នោះដែរ គឺបានបង្ហូចកិត្យានុភាពដល់ "អំណះអំណាងបែបទូទៅ៖ ថាវាជាការសន្និដ្ឋានដែលធ្វើឱ្យកន្លងផុតទៅដែលថានៅគ្រប់ករណីទាំងអស់ ភាពសម្ងាត់របស់កូនក្តីពីមុន *នឹង ឬ ត្រូវបាន* បំពានសម្រាប់មេធាវីការពារក្តី ដើម្បីតំណាងកូនក្តីបច្ចុប្បន្នឱ្យបានត្រឹមត្រូវ និងខ្លាំងក្លា"[40]។ សហព្រះរាជអាជ្ញាមិនធ្លាប់ដែលបានអះអាងថា ការរំលោភលើភាពសម្ងាត់ គឺជាសេចក្តីសន្និដ្ឋានមួយដែលចៀសមិនរួច នៅក្នុងគ្រប់រឿងក្តីទាំងអស់ នៃការតំណាងជាបន្តបន្ទាប់ទៀត នោះឡើយ។ ផ្ទុយទៅវិញការរំលោភបែបដូច្នេះ គឺជា *ការដែលអាចប្រមើលមើលបានយ៉ាងសមហេតុសមផល* នៅក្នុងកាលៈទេសៈជាក់លាក់ទាំងឡាយ ដែលសហមេធាវីចាត់តាំងបានធ្វើការជ្រើសរើសដាក់ខ្លួនឯងផ្ទាល់។ ក្នុងរឿងក្តី *Gotovina* អ្នកកាន់កាប់បញ្ជី និងអង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា ទាំងលោក Cayley[41] និង ទាំងលោក Kehoe[42] មិនអាចត្រូវបានគេនិយាយបានថា បានជាប់ទាក់ទិនដោយបុគ្គលផ្ទាល់ ឬយ៉ាងសំខាន់នៅក្នុងរឿងដែលកំពុងមានក្នុងដៃនោះឡើយ ដែលនេះច្បាស់ណាស់ថា មិនមែនជាស្ថានការណ៍ក្នុងករណីបច្ចុប្បន្ននេះទេ។

*(vi) ភាពត្រឹមត្រូវនៃចម្លើយតបពាក់ព័ន្ធនឹងច្បាប់យុត្តិសាស្ត្ររបស់តុលាការ ICTY និង អវតក*

---

[39] *ដដែលដូចមុន,* ត្រង់កថាខណ្ឌ ៥។

[40] **D56/9** ចម្លើយតបលើកទីពីរ, កំណត់សម្គាល់*ខាងលើ* លេខ១ ត្រង់កថាខណ្ឌ ១១។

[41] *រដ្ឋអាជ្ញា ទល់នឹង Ante Gotovina និងគូកន,* សំណុំរឿងលេខ IT-06-90-PT, សេចក្តីសម្រេចជាសាធារណៈ, ១៣ វិច្ឆិកា ២០០៧, ត្រង់ទំព័រទី ៥។

[42] *រដ្ឋអាជ្ញា ទល់នឹង Ante Gotovina និងគូកន,* សំណុំរឿងលេខ IT-06-90-PT, សេចក្តីសម្រេចលើញត្តិរួមរបស់ Ivan Cermak និង Mladen Markac ស្នើសុំឱ្យដោះស្រាយទំនាស់ផលប្រយោជន៍ពាក់ព័ន្ធនឹង Gregory Kehoe, ២៩ វិច្ឆិកា ២០០៧, ត្រង់ទំព័រទី ១០។

១៧- នៅក្នុងសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ចម្លើយតបនេះគឺ ទាំងថ្លែងមិនបានត្រឹមត្រូវ និងទាំងបានកំណត់ដោយភាន់ច្រឡំនូវច្បាប់យុត្តិសាស្ត្ររបស់តុលាការ ICTY និង អវតក។ ចម្លើយតបនេះមិនបានធ្វើឱ្យឃើញមានការខុសគ្នាជាស្រេចបាច់ រវាងរឿងក្ដីនានានៅ តុលាការ ICTY ដែលក្រុមមេធាវីការពារក្ដីបានបម្រើការងារពីមុន ជាមួយនឹងការិយាល័យអយ្យការ នៅក្នុងរឿងក្ដីនានាដែលមានជាប់ពាក់ព័ន្ធនឹងក្រុមមេធាវីការពារក្ដី ដែលធ្វើតំណាងឱ្យជនជាប់ចោទជាច្រើនរូបដែលត្រូវបានបញ្ជូនទៅជំនុំជម្រះពីអង្គហេតុស្រដៀងៗគ្នានោះឡើយ។ ការពិនិត្យឡើងវិញមួយនៃច្បាប់យុត្តិសាស្ត្ររបស់តុលាការ ICTY បានគាំទ្រដល់គោលជំហរដែលថា បទដ្ឋាននៃសក្ខីកម្ម ចំពោះទំនាស់ផលប្រយោជន៍ បានធ្វើយុត្តិកម្មដោយខុសៗគ្នានៅក្នុងនាដកថាទាំងពីរនេះ។

១៨- ខណៈដែលក្រុមមេធាវីការពារក្ដីបានបម្រើពីមុននៅក្នុងការិយាល័យអយ្យការ អង្គជំនុំជម្រះសាលាដំបូង ទីIII នៃតុលាការ ICTY បានរកឃើញថា ទំនាស់ផលប្រយោជន៍នឹងត្រូវបានបង្កើតឡើងកាលណាក្រុមមេធាវីការពារក្ដី "ដែលបានធ្វើការឱ្យអយ្យការ អំពីរឿងក្ដីតែមួយដូចគ្នាបេះបិទ ប្រឆាំងនឹងជនជាប់ចោទមួយនេះឯង"[43]។ យ៉ាងណាក៏ដោយ ដូចដែលបានពន្យល់បកស្រាយនៅខាងលើដូច្នោះដែរ ការណ៍នេះមិនមែនជារឿងក្ដីសម្រាប់ក្រុមមេធាវីការពារក្ដី ធ្វើជាតំណាងឱ្យជនជាប់ចោទជាច្រើនរូបនៅក្នុងកិច្ចដំណើរការនីតិវិធីជាបន្តបន្ទាប់ទៀតនោះឡើយ កាលណាមានបទដ្ឋានដែលកំពុងស្ថិតនៅជាធរមាននោះនៅតែមាន*ភាពដែលអាចប្រមើលមើលបានយ៉ាងសមហេតុសមផលអំពីទំនាស់*នៅឡើយនោះ។ ដូចដែលបានសំអាងនៅខាងលើដូច្នោះដែរ យុត្តិសាស្ត្ររបស់មេធាវីការពារក្ដីដែលមានជាប់ទាក់ទិននឹងជនជាប់ចោទជាច្រើនរូប ដែលត្រូវបានបញ្ជូនទៅជំនុំជម្រះក្ដីចំពោះអង្គហេតុដែលស្រដៀងៗគ្នា គឺនឹងមានលក្ខណៈស្មុគស្មាញខ្លាំងបំផុត និងមានការវិវត្តន៍ជាញឹកញាប់[44]។ ជាញឹកញាប់ ទ្រឹស្ដីទាំងឡាយដែលជជែកតវ៉ាអំពីការទទួលខុសត្រូវខាង ព្រហ្មទណ្ឌ គឺអាស្រ័យនៅលើការបំពេញនូវការទទួលខុសត្រូវរបស់អ្នកដទៃទៀត បើប្រៀបធៀបទៅ នឹងការទទួលខុសត្រូវរបស់កូនក្ដីផ្ទាល់របស់នរណាម្នាក់។ ហេតុដូច្នេះ ជនជាប់ចោទដែលត្រូវបាន ចោទប្រកាន់ នៅលើមូលដ្ឋាននៃអង្គហេតុនានាដែលស្រដៀងគ្នា គឺមានភាពទំនងយ៉ាងខ្លាំងដែលថា នឹងមានការជាប់ទាក់ទិនគ្នាទៅវិញទៅមក នៅពេលដែលមានការជំរុញទៅមុខនូវយុត្តិសាស្ត្ររបស់ មេធាវីការពារក្ដី។

---

[43] *រដ្ឋអាជ្ញា ទល់នឹង Enver Hadžihasanović,* សំណុំរឿងលេខ IT-01-47-PT, សេចក្ដីសម្រេចលើញត្តិរបស់អយ្យការ ស្នើសុំឱ្យពិនិត្យឡើងវិញលើសេចក្ដីសម្រេចរបស់អ្នកកាប់កាប់បញ្ជី ក្នុងការចាត់តាំងលោក Rodney Dixon ជាសហ មេធាវីការពារក្ដីឱ្យជនជាប់ចោទ Kubura (អង្គជំនុំជម្រះសាលាដំបូង ទីII នៃតុលាការ ICTY), ២៦ មីនា ២០០២, ត្រង់កថាខណ្ឌ ៥៦។

[44] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើរឿងក្ដី *Prlić*, កំណត់សម្គាល់*ខាងលើ* លេខ២៤ ត្រង់កថាខណ្ឌ ២៩។

១៩- សហមេធាវីចាត់តាំង ក៏ប៉ុនប៉ងផងដែរក្នុងការបកស្រាយបង្ហាញថា ការសុខចិត្តស្រុះស្រួលរបស់ អវតក នៅក្នុងទំនាស់ផលប្រយោជន៍តាមរយៈការដាក់បណ្ដឹងសារជាថ្មីលើបញ្ហាដែលបានដោះស្រាយរួចស្ដីពី ការផ្លាស់ប្ដូរបុគ្គលិកពីការិយាល័យសហព្រះរាជអាជ្ញា ឲ្យទៅការិយាល័យសហចៅក្រមស៊ើបអង្កេត[45]។ សហចៅក្រមស៊ើបអង្កេត កាលពីខែឧសភា ឆ្នាំ២០០៩[46] និងខែមេសា ឆ្នាំ២០១០[47] បានបង្គាប់យ៉ាងជាក់លាក់ដល់លោក អាង ឧត្តម និងលោក Michael Karnavas កុំឲ្យដាក់ឯកសារតទៅទៀតលើបញ្ហានេះ។

២០- សំណើមួយសុំបដិសេធនូវគុណវុឌ្ឍិរបស់ Stephen Heder និង David Boyle ត្រូវបានរកឃើញថា មិនអាចទទួលយកបានពីសំណាក់អង្គបុរេជំនុំជម្រះ កាលពីថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០០៩[48]។ ក្រោយមក អង្គបុរេជំនុំជម្រះបានបដិសេធសំណើមួយដែលស្នើសុំឲ្យ ធ្វើមោឃភាពលើ កិច្ចស៊ើបសួរទាំងអស់ដែលបានបំពេញដោយ ឬដោយមានជំនួយពី Stephen Heder និង David Boyle។ អង្គបុរេជំនុំជម្រះបានសម្រេចថា "ដោយផ្អែកទៅលើកត្តាទាំងអស់នេះ មិនមានអ្វីដែលអាចធ្វើជាយុត្តិកម្មដើម្បីសុំទៅអង្គបុរេជំនុំជម្រះឲ្យសម្រេចមោឃភាពទេ៖ អាស្រ័យដោយមិនមានវិការៈនៃនីតិវិធីណាមួយនោះ មិនមានសិទ្ធិណាមួយរបស់មេធាវីការពារក្ដី ដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងនយោបាយ ត្រូវបានរំលោភទេ"[49]។

### *(vii) ភាពមិនអាចផ្សះផ្សាបានបាននៃទំនាស់ផលប្រយោជន៍ដែល កំពុងមានអត្ថិភាព ឬ ដ៏មានសក្ដានុពល*

២១- សហមេធាវីចាត់តាំង មិនទំនងជាជជែកតវ៉ាអំពីការដាក់ឯកសារដែលថា ការលះបង់មួយនឹងប្រែទៅជាមិនមានប្រសិទ្ធិភាពកាលណាទំនាស់ផលប្រយោជន៍មួយមិនអាចត្រូវផ្សះផ្សាបាន នោះទេ។ ដូច

---

[45] **D56/9** ចម្លើយតបលើកទីពីរ, កំណត់សម្គាល់*ខាងលើ* លេខ១ ត្រង់កថាខណ្ឌ ៣៨។

[46] **CF002-A252/2**, លិខិតដែលមានចំណងជើងថា "សំណើរបស់មេធាវីស្នើសុំព័ត៌មានពាក់ព័ន្ធនឹងលោក Stephen Heder", ២៩ ឧសភា ២០០៩។

[47] **CF002-D377/1**, លិខិត "យោង៖ សំណើរបស់អៀងសារីសុំដាក់កម្រិតវិសាលភាពនៃភារកិច្ចរបស់អ្នកស៊ើបអង្កេត កសចស Stephen Heder", ២៩ មេសា ២០១០។

[48] **CF002-3 (អបជ)** សេចក្ដីសម្រេចលើសំណើរបស់ជនត្រូវចោទស្នើសុំបដិសេធគុណវិឌ្ឍិរបស់បណ្ឌិត Stephen Heder និង David Boyle, ២២ កញ្ញា ២០០៩។

[49] **CF002-D402**, ដីកាសម្រេចបដិសេធពាក្យសុំមោឃភាពធ្វើឡើងដោយ អៀង សារី (**D381** និង **D387**), ៣ កញ្ញា ២០១០, ត្រង់កថាខណ្ឌ ១២។

ដែលសហព្រះរាជអាជ្ញា បានដាក់ជូននូវសេចក្តីសន្និដ្ឋានពីមុនមកដូច្នោះដែរ តេស្តតាមផ្លូវច្បាប់អំពីថា តើទំនាស់ផលប្រយោជន៍អាចត្រូវបានលះបង់ ឬមិនអាចត្រូវផ្សះផ្សាបាន គឺជាបញ្ហាដាច់ដោយឡែកពីគ្នាក្នុងការបង្កើតភាពដែលអាចប្រមើលមើលបានយ៉ាងសមហេតុសមផលអំពីទំនាស់ផលប្រយោជន៍ ឬមួយយ៉ាងណា[50]។ តេស្តនេះ មានការវាយតម្លៃថា តើការតំណាងនោះវាជាការលំអៀងដែលមិនអាចប្រែត្រឡប់បាន ទៅលើការគ្រប់គ្រងខាងកិច្ចការរដ្ឋបាលតុលាការ ដែរឬទេ។

២២- សហមេធាវីចាត់តាំងចោទថា អំណះអំណាងនៅក្នុងសេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញា ស្តីពីទំនាស់ផលប្រយោជន៍ ដែលលើកអំពីបញ្ហាស្តីពីទំនុកចិត្តរបស់សាធារណជន នៅក្នុងការគ្រប់គ្រងកិច្ចការរដ្ឋបាលតុលាការ គឺស្មើនឹងអំណះអំណាងថ្មីដែលមិនជាប់ទាក់ទងទៅនឹងសំណើនេះទេ[51]។ នេះគឺជាការមិនត្រឹមត្រូវទេ។ ផលប៉ះពាល់នៃតំណាងទ្វេពីសំណាក់ក្រុមមេធាវីការពារក្តី ទៅលើទំនុកចិត្តរបស់សាធារណជន នៅក្នុងការគ្រប់គ្រងកិច្ចការរដ្ឋបាលតុលាការ គឺជាកត្តាមួយក្នុងចំណោមកត្តានានា ដែលគេត្រូវធ្វើការពិចារណានៅក្នុងការវាយតម្លៃថាតើ ទំនាស់ផលប្រយោជន៍ជាក់លាក់ណាមួយអាច ឬមិនអាចផ្សះផ្សាបានដែរឬអត់។ អំណះអំណាងនេះ ពីដំបូងឡើយ ត្រូវបានគេធ្វើឲ្យវាមានការជឿនលឿនទៅមុខនៅក្នុងសំណើដំបូងរបស់សហព្រះរាជអាជ្ញា[52]។

## IV. **នៅក្នុងឆ្លើយតបបានយកច្បាប់មកអនុវត្តខុសនឹងអង្គហេតុ**

*(i) ភស្តុតាងបឋមអំពីភាពដែលអាចព្យាករណ៍ទុកជាមុនបានស្តីពីទំនាស់ផលប្រយោជន៍ដ៏ច្រើន*

២៣- ដូចបានលើកសំអាងខាងលើនេះ យុត្តិសាស្ត្ររបស់តុលាការ ICTY បានបង្ហាញឲ្យឃើញថា ការធ្វើតេស្តសាកល្បងតាមបែបសត្យានុម័ត សំរាប់ទំនាស់ផលប្រយោជន៍ គឺវាតម្រូវឲ្យមានភាពអាចព្យាករទុកជាមុនបានដោយសមហេតុសមផល, ការយល់ឃើញនៃសមត្ថកិច្ចនានា របស់តុលាការទៅលើភស្តុតាង *បឋម*ទាំងមូល។ មេធាវីតែងតាំងអនុម័តនូវយុទ្ធសាស្ត្រនៃភស្តុតាងមួយចំណែកម្តងៗនៅក្នុងការឆ្លើយតបទៅនឹងអង្គហេតុដែលបានលើកយកមកធ្វើអំណះអំណាងដោយសហព្រះរាជអាជ្ញា ដែលបង្ហាញឲ្យឃើញអំពីអត្ថិភាពឬភាពអាចព្យាករទុកជាមុនបានដោយសមហេតុសមផលអំពីមានទំនាស់ផលប្រយោជន៍ដ៏ច្រើន។ ដើម្បីគោលបំណងនេះ សហមេធាវីតែងតាំងបានចោទប្រកាន់ថា អង្គហេតុ

---

[50] សូមអាន **D56/7** សេចក្តីសន្និដ្ឋានបន្ថែម, កំណត់សម្គាល់*ខាងលើ* លេខ២ ត្រង់កថាខណ្ឌ ៧០-៧៧។

[51] **D56/9** *ដដែលដូចមុន*, ត្រង់កថាខណ្ឌ ១។

[52] **D56/1** សំណើ, កំណត់សម្គាល់*ខាងលើ* លេខ៣ ត្រង់កថាខណ្ឌ ២២ និង ៥២-៥៣។

មួយចំនួនដែលបានលើកយកមកសំអាងដោយសហព្រះរាជអាជ្ញាអន្តរជាតិ - ដែលសំខាន់ទាក់ទងទៅនឹងសេចក្តីប្រកាសព័ត៌មានមួយរបស់ មាស មុត និងគេហទំព័ររបស់ក្រុមមេធាវីការពារក្តីរបស់ អៀង សារី-គឺជាការធ្វើដោយស្មានៗ[53]។ គ្មានការអះអាងណាមួយក្នុងចំណោមការអះអាងទាំងនេះ បានផ្តោតទៅលើភស្តុតាងស្នូលរបស់សហព្រះរាជអាជ្ញាថា ទំនាស់ផលប្រយោជន៍ណាមួយមានអត្ថិភាព ឬក៏អាចត្រូវបានព្យាករណ៍ទុកជាមុនដោយសមហេតុសមផលនោះឡើយ។ ភស្តុតាងនេះបានផ្អែកលើមូលដ្ឋាននៃអង្គហេតុចោទប្រកាន់ទាំងឡាយដែលនៅក្នុងណុំរឿង[54]។

២៤-មានភស្តុតាងគ្រប់គ្រាន់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត សំរាប់បង្ហាញឲ្យឃើញអំពីភាពដែលអាចព្យាករណ៍ទុកជាមុនបានដោយសមហេតុសមផល អំពីទំនាស់ផលប្រយោជន៍ដែលផ្អែកលើអង្គហេតុនានាដូចដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះហើយដែលត្រូវបានគាំទ្រដូចនៅក្នុងសំណុំរឿងនេះ។ ទាំងពីរនាក់ មាស មុត នឹង អៀង សារី សុទ្ធតែត្រូវបានចោទប្រកាន់ថាបាន ចូលរួមនៅក្នុងឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងការផ្ទេរបញ្ជូនកម្មាភិបាលនានានៃកងពលធំលេខ១៦៤ ដែលត្រូវបានបោសសំអាត ហើយនិងជនជាតិថៃ ជនជាតិវៀតណាម និងពួកអ្នកដើរកប៉ាល់មកពីប្រទេសលោកខាងលិច ទៅកាន់មន្ទីរស-២១[55]។ លើសពីនេះទៀត ពួកគេទាំងពីរនាក់ត្រូវបានចោទប្រកាន់ថាបានចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមតែមួយ និងធ្លាប់ជាសមាជិកនៅក្នុងគណៈកម្មាធិការជាន់ខ្ពស់ នៃកម្ពុជាប្រជាធិបតេយ្យតែមួយជាមួយគ្នា[56]។ មុខតំណែងណាមួយក៏ដោយសុទ្ធតែមានភស្តុតាង *បឋម*ដែលបង្ហាញថា អៀង សារី គឺជាមនុស្សម្នាក់ដែល មាស មុត បានរាយការណ៍ជូន[57]។ មាស មុត គឺជាលេខានៃកងពលធំលេខ១៦៤ ដែលបានដំណើរការកងទ័ពជើងទឹកនៃកម្ពុជាប្រជាធិបតេយ្យ[58]។ នៅក្នុងមុខតំណែងនេះ គាត់បានរាយការណ៍ដោយផ្ទាល់ជូនប្រធាននៃអគ្គសេនាធិការ (និង

---

[53] ឯកសារលេខ **D56/9** ចម្លើយតបលើកទីពីរ,កំណត់សំគាល់លេខ១ *ខាងដើម*, ត្រង់កថាខណ្ឌពីទី៣១-៣២, ៣៤-៣៥, ៤៦-៤៩.

[54] ឯកសារលេខ **D56/7** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យសើបសួរបន្ថែម, កំណត់សំគាល់លេខ២ *ខាងដើម,* ត្រង់កថាខណ្ឌពីទី ៤៩-៦៩។

[55] ឯកសារលេខ **D56/7** *ដូចគ្នានឹងខាងលើ* , ត្រង់កថាខណ្ឌពីទី៤៩-៥០ និង ទី៥៨។

[56] *ដូចគ្នានឹងខាងលើ* , ត្រង់កថាខណ្ឌពីទី៥៩។ សូមអានផងដែរ ឯកសារលេខ **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ ស្តីពីកងទ័ពបដិវត្តន៍នៃកម្ពុជាប្រជាធិបតេយ្យ, ចុះថ្ងៃទី២០ វិច្ឆិកា ២០០៨ ត្រង់កថាខណ្ឌទី៣ (“ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ”)។

[57] ឯកសារលេខ **D56/7** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យសើបសួរបន្ថែម, កំណត់សំគាល់លេខ២ *ខាងដើម,* ត្រង់កថាខណ្ឌទី៦០។

[58] ឯកសារលេខ**D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ, កំណត់សំគាល់លេខ៦៨ *ខាងដើម,* ត្រង់កថាខណ្ឌទី១៤និងទី៨២ និងបានលើកសំអាងលើប្រភពនានានៃភស្តុតាង។

សមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍) សុន សេន *ហៅ* ខៀវ[59]។ ចំណែកឯ សុន សេន វិញ ត្រូវរាយការណ៍ជូនសមាជិកផ្សេងៗទៀតនៃគណៈកម្មាធិការអចិន្ត្រៃយ៍។

២៥-ឧទាហរណ៍ដូចជា មានទូរលេខយោធាសំងាត់មួយចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៧ ហើយដែលបានបញ្ជាក់យថាភូតិដោយសាក្សីនៃសំណុំរឿង០០២ឈ្មោះ មាស វឿន (Meas Voeun)[60] ទាក់ទងនឹងការចាប់ខ្លួនជនជាតិថៃ៤នាក់ និងជនជាតិខ្មែរម្នាក់នៅក្នុងសមុទ្រកោះកុងដែលក្នុងនោះរួមបញ្ចូលនូវចំណារ ដូចខាងក្រោមនេះដែលចារដោយ សុន សេន ដែលផ្តល់ជាភស្តុតាង*បឋម* ឲ្យឃើញអំពីខ្សែរយៈនៃការរាយការណ៍រវាង មាស មុត និងមេដឹកនាំជាន់ខ្ពស់នានានៃកម្ពុជាប្រជាធិបតេយ្យ រួមទាំង អៀង សារី ក្នុងនោះផង៖ "(១) ជូនអង្គការដើម្បីជ្រាបជាព័ត៌មាន។ (២) ផ្អែកលើរបាយការណ៍ផ្ទាល់មាត់របស់សមមិត្ត មុត, កាលពីម្សិលមិញយើងចាប់បានកាណូតមួយគ្រឿង..."[61]។ នីរសាឈ្មោះ ពាន ឃាន (Pean Khean) បានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង លេខ០០២ថា៖ "ចាប់ពីពេលនោះមក ពាក្យ"អង្គការ" គឺសំដៅទៅលើដឹកនាំនានារបស់បដិវត្តន៍កម្ពុជា[...] ក្នុងឆ្នាំ១៩៧៦ ខ្ញុំបានចាប់ផ្តើមស្គាល់ពួកមេដឹកនាំជាន់ខ្ពស់ទាំងនោះ"។ ក្នុងចំណោមមេដឹកនាំជាន់ខ្ពស់ទាំងនេះរួមមាន [...] អៀង សារី ផងដែរ[62]។

២៦-ស្រដៀងគ្នានេះដែរ មានកំណត់ត្រានៃទូរសព្ទសម្ងាត់យោធាមួយដែលបានហៅដោយ មាស មុត ដែលរាយការណ៍ស្តីពីការសម្លាប់ជនជាតិវៀតណាម ចំនួន១២០នាក់ និងការបន្តឃុំខ្លួនជនជាតិថៃ ("ជនជាតិសៀម") ដែលត្រូវបានចម្លងជូនទៅឲ្យ"បងវ៉ាន់"ឈ្មោះហៅក្រៅដែលគេស្គាល់ថាជាឈ្មោះរបស់ អៀងសារី[63]។ នេះគឺជាការផ្តល់នូវភស្តុតាង*បឋម* ស្តីពីការប្រាស្រ័យទាក់ទងដោយផ្ទាល់ដែលចោទប្រកាន់ថាបានធ្វើពី មាស មុត ទៅកាន់ អៀង សារី។ ហើយក៏មានភស្តុតាងផងដែរថា អៀង

---

[59] សូមអាន **CF002-E1/130.1** ប្រតិចារិក, ចុះថ្ងៃទី៤ តុលា ២០១២ ត្រង់ទំព័រ៣៣៤, ជួរបន្ទាត់ពីទី២១-២៣, ដែលសាក្សីមាស វឿន Meas Vouen (មិនជាប់សាច់ញាតិជាមួយមាស មុតទេ) បានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿងលេខ០០២ថា "នៅថ្នាក់អគ្គសេនាធិការ, ខៀវ គឺសំដៅទៅលើ សុន សេន"។

[60] **CF002-E1/130.1** ប្រតិចារិក, ចុះថ្ងៃទី៤តុលា ២០១២ ត្រង់ទំព័រទី៣២-៣៥។

[61] ឯកសារលេខ **D1.3.34.23 [CF002-E3/1031]** សារទូរលេខលេខ២៨ ចុះថ្ងៃទី១២ សីហា ១៩៧៧, ត្រង់លេខ ERN 00233655។

[62] **CF002-E1/71.1** ប្រតិចារិក, ចុះថ្ងៃទី១៩ កញ្ញា ២០១២ ត្រង់ទំព័រទី៦៩ ជួរបន្ទាត់ពីទី១៥-១៦, ទី២៥, និងទំព័រ៧០, ជួរបន្ទាត់ទី១។

[63] ឯកសារលេខ **D56/3.4** ទូរស័ព្ទសម្ងាត់ ចុះថ្ងៃទី១ មេសា ១៩៧៨។សូមអានផងដែរឯកសារលេខ **D54/8** ចម្លើយសាក្សី ដុល សុង (Dol Song)ដែលស្រង់ដោយ OCIJ ត្រង់លេខ ERN ភាសាខ្មែរលេខ 00936681 [ការបកប្រែជាភាសាអង់គ្លេសមិនទាន់មានស្រាប់នៅឡើយទេ]។

សារី ត្រូវបានគេចម្លងជូននៅក្នុងករណីផ្សេងៗទៀត អំពីការជាប់ពាក់ព័ន្ធទៅនឹងលិខិតឆ្លើយឆ្លងដែលផ្ញើមកពី មាស មុត[64]។

២៧-នៅគ្រប់ពេលវេលាដែលសំខាន់ៗអស់ទាក់ទងនឹងសំណុំរឿងលេខ០០៣ អៀង សារី គឺជាសមាជិកពេញសិទ្ធិមួយរូបក្នុងចំណោមសមាជិកពេញសិទ្ធិទាំងប្រាំរូប នៃគណៈកម្មាធិការអចិន្ត្រៃយ៍ដែលបានចូលរួមចូលរួមនៅក្នុងអង្គប្រជុំនានារបស់គណៈកម្មាធិការនេះ ហើយដែលមានឈ្មោះនៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំទាំងនេះ[65]។ យោងទៅលើអង្គប្រជុំមួយរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ដែលក្នុងនោះ អៀង សារី បានចូលរួម[66] អ្នកជំនាញ David Chandler បានទាញសេចក្ដីសន្និដ្ឋានថា "សេចក្ដីសំរេចទាំងឡាយ [...] ត្រូវបានធ្វើឡើងជាសមូហភាពដោយអង្គការខ្លួនឯងផ្ទាល់ - និយាយម្យ៉ាងទៀតថា ដោយពួកអ្នកដែលបានចូលរួមក្នុងអង្គប្រជុំ"[67]។ គាត់បានផ្ដល់សក្ខីកម្មបន្ថែមទៀតថា "ប្រាកដណាស់" សមាជិកទាំងឡាយនៃគណៈកម្មាធិការអចិន្ត្រៃយ៍សុទ្ធតែបានទទួលនូវច្បាប់ចម្លងនៃកំណត់ហេតុប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍[68]។

២៨-សរុបឲ្យខ្លីមក នៅក្នុងភស្តុតាងទាំងឡាយដែលមានស្រាប់នៅក្នុងដំណាក់កាលដំបូងនៃការស៊ើបសួរនេះ ការទាញសេចក្ដីសន្និដ្ឋានដែលមានតក្កភាពជាងគេបំផុតនោះគឺ មាស មុត បានរាយការណ៍ទាំងដោយផ្ទាល់ និងដោយប្រយោលជូនទៅ អៀង សារី។

២៩-សហព្រះរាជអាជ្ញាបានធ្វើការបង្ហាញជូនមួយដោយជាក់លាក់រួចហើយអំពីថា បច្ចុប្បន្ននេះតើតាមការជាក់ស្ដែងផលប្រយោជន៍របស់ អៀង សារី និង មាស មុត មានភាពទំនាស់នឹងគ្នាបែបដូចម្ដេច

[64] ឯកសារលេខ**D56/7** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យសើបសួរបន្ថែម, កំណត់សំគាល់លេខ២ *ខាងដើម,* ត្រង់កថាខណ្ឌទី៥២,និងទី៦០។ ឯកសារលេខ **D.1.3.34.60** សារទូរលេខយោធានៃកម្ពុជាប្រជាធិបតេយ្យដោយមាស មុត ដែលមានជំណងជើងថា "សារទូរលេខ០០- បង់វិទ្យុលេខ៣៥៤ - គោរពជូនមកគណៈកម្មាធិការមន្ទីរ៨៧០"។សូមអានឯកសារលេខ **D4.1.635** ការហៅទូរស័ព្ទជាសម្ងាត់កាលពីថ្ងៃទី១ មេសា ១៩៧៨ ។ សូមអានផងដែរ ឯកសារលេខ **D54/11** គំណត់ហេតុចម្លើយរបស់ ម៉ឺ រ៉េត (Meu Ret) ដែលស្រង់ដោយ OCIJ, ត្រង់លេខ ERN ជាភាសាខ្មែរ លេខ 00936712 [សំណៅបកប្រែជាភាសាអង់គ្លេសមិនមានទេ]។

[65] ឯកសារលេខ**D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ, កំណត់សំគាល់លេខ៦៨ *ខាងដើម ត្រង់កថាខណ្ឌពីទី* ១២២។ ឯកសារលេខ **D4.1.1032 [CF002-E3/94]** កំណត់ហេតុនៃការធ្វើសម្ភាសន៍ អៀង សារី ដោយលោកស្រី Elizabeth Becker, ចុះថ្ងៃទី ២២ កក្កដា ១៩៨១, លេខ ERN 00342500-00342504។

[66] ឯកសារលេខ **D1.3.27.6 [CF002-E3/221]** កំណត់ហេតុប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍, ចុះថ្ងៃទី១៤ ឧសភា ១៩៧៦។

[67] **CF002-E1/91.1** ប្រតិចារិក, ចុះថ្ងៃទី១៨ កក្កដា ២០១២, ត្រង់ទំព័រ៤២ , ជួរបន្ទាត់ទី ១៨-២១។

[68] **CF002-E1/91.1** *ដូចគ្នានឹងខាងលើ,* ត្រង់ទំព័រ២៦ , ជួរបន្ទាត់ទី ១៤-១៥។

ខ្លះ? (ឬមានភាពសមហេតុសមផលថា ទំនងជាក្លាយទៅជាយ៉ាងនេះ) នៅក្នុងអម្លុងពេលនៃកិច្ចដំណើរការនីតិវិធីនៃរឿងក្តីដែលក្នុងនោះពួកគេទាំងពីរនាក់ សុទ្ធតែត្រូវបានចោទប្រកាន់ថាជាអ្នកដែលបានចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមតែមួយ និងជាសមាជិកនៃគណៈកម្មាធិការជាន់ខ្ពស់របស់ បកក តែមួយជាមួយគ្នា[69]។ សហព្រះរាជអាជ្ញាក៏បានបង្ហាញឱ្យឃើញផងដែរថា តើសហមេធាវីតែងតាំងទទួលបានព័ត៌មានតាមបែបដូចម្តេចខ្លះ នៅក្នុងអម្លុងពេលនៃការធ្វើបទបង្ហាញរបស់ពួកគេ ស្តីពី អៀង សារី នោះ? - ជាពិសេសទាក់ទងនឹងការអនុវត្តន៍គោលនយោបាយរបស់ បកក តាមជាក់ស្តែងការដឹងអំពីការចាប់ខ្លួន, ការឃុំខ្លួន, ការបោសសំអាត, និងអំពីខ្សែរយៈសំរាប់ការរាយការណ៍-ដែលអាចសំខាន់សំរាប់មេធាវីការពារក្តីរបស់ មាស មុត[70] ក៏ប៉ុន្តែខូចខាតដល់ផលប្រយោជន៍ខាងផ្លូវច្បាប់របស់ អៀង សារី ទាក់ទងនឹងកិត្តិនាម សេចក្តីថ្លៃថ្នូរ និងសិទ្ធិឯកជន ដែលប្រគល់ឱ្យទៅអ្នកស្នងមត៌ករបស់គាត់បន្ទាប់ពីគាត់ទទួលមរណភាពទៅ[71] ឬមួយវិញទៀត អាចជាអត្ថប្រយោជន៍ដល់ មាស មុត ក្នុងការកំរិតចំពោះកាតព្វកិច្ចផ្សេងៗដែលត្រូវតបស្នងទៅ អៀង សារី វិញតាមរយៈអ្នកស្នងមត៌ករបស់គាត់[72] ឬក៏កំរិតចំពោះភក្តីភាពដែលមិនមានជាប់ចំណងខាងផ្លូវកាយឬផ្លូវចិត្ត ដែលមេធាវីការពារក្តីតែងតាំងបានជំពាក់ មាស មុត[73]។

៣០-អាស្រ័យហេតុនេះហើយ សហព្រះរាជអាជ្ញាអន្តរជាតិ សូមបញ្ជាក់សារជាថ្មីឡើងវិញអំពីគោលជំហររបស់ខ្លួនថា "តំបន់គ្រោះថ្នាក់" ទាំងប្រាំ[74] និងទំនាស់ផលប្រយោជន៍ផ្សេងៗដែលកើតចេញពីភូមិភាគខាងលើនេះ សុទ្ធតែអាចឱ្យព្យាករទុកជាមុនបានដោយសមហេតុសមផលទៅតាមកាលៈទេសៈ។

៣១- សហមេធាវីចាត់តាំងកំណត់ចរិកលក្ខណៈចម្លើយរបស់ មាស មុត ដែលដាក់ការទទួលខុសត្រូវទៅលើ អៀង សារី ដូចជា "ការដកស្រង់សំដីរបស់សារព័ត៌មាន មួយចំនួនដែលមានចុះកាលបរិច្ឆេទ"[75]។ ផ្ទុយទៅវិញ នៅក្នុងអត្ថបទនេះ មាស មុត បានដាក់ការទទួលខុសត្រូវដោយផ្ទាល់ទៅលើ អៀង សារី ហើយខំស្វែងរកលើកទោសឱ្យខ្លួនឯង ដើម្បីរួចផុតពីការទទួលខុសត្រូវតាមទម្រង់ណាមួយក៏ដោយ។

---

[69] ឯកសារលេខ **D56/7** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យសើបសួរបន្ថែម, កំណត់សំគាល់លេខ២ *ខាងដើមត្រង់កថាខណ្ឌពីទី* ៥៨-៦០។

[70] ឯកសារលេខ **D56/7** *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី៦៣។

[71] ឯកសារលេខ **D56/7** *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី១៦-១៨។

[72] ឯកសារលេខ **D56/7** *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី៦៨។

[73] ឯកសារលេខ **D56/7** *ដូចគ្នានឹងខាងលើ* ។

[74] កំណត់សំគាល់លេខ២១ *ខាងដើម*។

[75] ឯកសារលេខ **D56/9** ចម្លើយតបលើកទីពីរ កំណត់សំគាល់លេខ១ *ខាងដើម* ត្រង់កថាខណ្ឌទី៣៤។

ក្នុងខណៈដែលមេធាវីការពារក្តីមានសេរីភាពក្នុងការសួរដេញដោល អំពីភាពត្រឹមត្រូវនៃចម្លើយនេះ សំដីរបស់ មាស មុត ខ្លួនឯងផ្ទាល់ដូចដែលបានរាយការណ៍ជូនរួចហើយ បានផ្តល់នូវភស្តុតាង*បឋម* ថាផលប្រយោជន៍របស់ខ្លួន និងផលប្រយោជន៍ទាំងឡាយរបស់ អៀង សារី ត្រូវបានខូចខាតយ៉ាងខ្លាំង នៅក្នុងពេលបច្ចុប្បន្ននេះ។ គឺច្បាស់ជាដើម្បីផលប្រយោជន៍របស់ អៀង សារី ក្នុងការដែលធ្វើឱ្យគេលែងជឿទុកចិត្តទៅលើចម្លើយរបស់ មាស មុត ដោយប្រសិនជាពិតមែននោះ ចម្លើយនោះនឹងធ្វើឱ្យ មាស មុត រួចចាកផុតពីការទទួលខុសត្រូវ។ ទំនាស់ផលប្រយោជន៍សំរាប់មេធាវីការពារក្តី គឺវាច្បាស់ណាស់ ។ ដូចជានៅក្នុងករណីរឿងក្តីរបស់ *Mejakić* បើសិនជាទំនាស់មិនត្រូវបានដោះស្រាយឥឡូវនេះទេនោះ “ការគ្រប់គ្រងកិច្ចការរដ្ឋបាលនៃវិស័យយុត្តិធម៌ អាចនឹងមានភាពលំអៀងដោយមិនអាចប្រែត្រឡប់វិញបានឡើយ”[76]។ វានឹងមានការប៉ះពាល់ទៅដល់សេចក្តីសំរេចណាមួយដោយ មាស មុត ក្នុងការផ្តល់ភស្តុតាងទៅឱ្យសហចៅក្រមស៊ើបអង្កេត នៅក្នុងសំណុំរឿងលេ០០៣ ហើយនឹងទៅឱ្យ អង្គជំនុំជម្រះនៅក្នុងសំណុំរឿងលេខ០០២។ ហើយក៏អាចមានហានិភ័យផងដែរថាលោក ឧត្តម និង លោក Karnavas “អាចនឹងដកខ្លួនចេញនៅក្នុងអម្លុងពេលនៃការ[ស៊ើបសួរ] ពីព្រោះហេតុដូចនេះ ទំនាស់ផលប្រយោជន៍នឹងធ្វើឱ្យកិច្ចដំណើរការនីតិវិធីត្រូវរអូសបន្លាយ”[77]។

៣២- ចម្លើយតបបានការពារសិទ្ធក្នុងការនៅស្ងៀមមិនឆ្លើយរបស់ មាស មុត ដែលស្របតាមវដ្តធម្មនុញ្ញ ដែលទាក់ទងនឹងសេចក្តីសំរេចនេះ មិនផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿងលេខ០០២ ឡើយ[78]។ សហព្រះរាជអាជ្ញាមិនបានជូនសេចក្តីសន្និដ្ឋានថា *មូលហេតុ* នៃការមិនមានចេតនាក្នុងការផ្តល់សក្ខីកម្មរបស់ មាស មុត នោះគឺពុំមានការជាប់ទាក់ទងទាល់តែសោះទៅនឹងបញ្ហានានាដែលកំពុងតែមានទំនាស់នោះឡើយ។ អ្វីដែលជាប់ទាក់ទងនោះគឺថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់អត្តសញ្ញាណ មាស មុត ថាជា សាក្សីដែលខ្លួនមានបំណងនឹងកោះហៅនៅក្នុងសំណុំរឿងលេខ០០២ និងថា មាស មុត នៅតែជាសាក្សីសក្តានុពលក្នុងសំណុំរឿង ០០២/០២ ដែលបើយោងតាមផែនការពិស្តាររបស់អង្គជំនុំជម្រះសាលាដំបូង នឹងមានបញ្ចូលទាំងបទចោទអំពីការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ និងការរកឃើញអំពីការប្រព្រឹត្តិចំពោះជនជាតិវៀតណាម ដែលជាបញ្ហាជាន់គ្នានៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរក្នុងសំណុំ

---

[76] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* Mejakić *និងគូរកន* សំណុំរឿងលេខ IT-02-65- AR73.1, សេចក្តីសំរេចលើបណ្តឹងសាទុក្ខដោយអយ្យការសុំឱ្យដោះស្រាយលើទំនាស់ផលប្រយោជន៍ៗទាក់ទងនឹងមេធាវី *Jovan Simić* (អង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៃតុលាការ ICTY), ចុះថ្ងៃទី៦ តុលា ២០០៤ត្រង់កថាខណ្ឌទី១៥។

[77] *ដូចគ្នានឹងខាងលើ*។

[78] ឯកសារលេខ **D56/9** *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី៤៥។

រឿង០០៣[79]។ បញ្ហានេះត្រូវបានធ្វើការពិចារណាដោយតុលាការ ICTY នៅក្នុងករណីរឿងក្តីរបស់ *Mejakić*[80]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ បានគាំទ្រនូវសេចក្តីសំរេចរបស់អង្គជំនុំជម្រះសាលាដំបូងថា មានទំនាស់ដោយសារមេធាវីការពារក្តីរបស់ជនជាប់ចោទ បានធ្វើជាតំណាងឲ្យជនជាប់ចោទម្នាក់ផ្សេងទៀត ដែលត្រូវបានកោះហៅឲ្យមកផ្តល់សក្ខីកម្មនៅក្នុងការជំនុំជម្រះក្តីរបស់ជនជាប់ចោទនេះ។ ចំណែកឯអង្គជំនុំជម្រះសាលាឧទ្ធរណ៍វិញបានធ្វើការកត់សំគាល់ថា សេចក្តីសំរេចនៅក្នុងការឲ្យផ្តល់សក្ខីកម្ម គឺស្ថិតនៅលើសាក្សីដែលមានសក្តានុពល អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានមានយោបល់ថា មេធាវីបានធ្វើឲ្យខ្លួនឯងមានទំនាស់ផលប្រយោជន៍ ដោយបរិយាយលំអិតថា៖

> *ក្នុងនាមជាមេធាវីការពារក្តីរបស់លោក* Prcać [មេធាវី] *លោក* Simić *មានកាតព្វកិច្ចត្រូវតែពិចារណាថា តើមានអត្ថប្រយោជន៍អ្វីខ្លះដែលលោក* Prcać *អាចនឹងទទួលបានពីកិច្ចសហប្រតិបត្តិការជាមួយខាងអយ្យការ ក្នុងការដែលគាត់ផ្តល់ដោយស្ម័គ្រចិត្តនូវភស្តុតាងប្រឆាំងនឹងលោក* Mejakić *នោះ។មួយវិញទៀត ក្នុងនាមជាមេធាវីការពារក្តីរបស់* Mejakić *លោក* Simić *ត្រូវមានកាតព្វកិច្ចក្នុងការធានាឲ្យប្រាកដថាផលប្រយោជន៍ដ៏ប្រសើរបំផុតរបស់លោក* Mejakić *ត្រូវបានការពារ។ នេះគឺរួមមានការចាត់នូវរាល់វិធានការណ៍តាមផ្លូវច្បាប់តាមដែលអាចធ្វើទៅបានដើម្បីធានាថា ភស្តុតាងរបស់លោក* Prcać *មិនត្រូវបានស្តាប់ ឬក៏ថាភស្តុតាងនោះមិនជំពាក់ទាក់ទងនឹងលោក* Mejakić *នោះទេ*[81] ។

៣៣- សហព្រះរាជអាជ្ញាមិនទាយស្មានតើហេតុអ្វីបានជា មាស មុត មិនបានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿងលេខ០០២ ហើយក៏មិនទាយស្មានអំពីចំណុចជាក់លាក់នានានៃការណែនាំរបស់សហមេធាវីតែងតាំងដល់ មាស មុត ស្តីពីបញ្ហានេះដែរ។ក្នុងនាមជាមេធាវីការពារក្តីឲ្យ អៀង សារី ដែលមានភារកិច្ចផ្តល់ឲ្យទៅតាមជំនាញវិជ្ជាជីវៈ និងក្រមសីលធម៌ដែលកំពុងត្រូវបានទទួលស្គាល់នោះ សហមេធាវីតែងតាំងគួរតែបានខំធ្វើការតស៊ូដើម្បីការពារផលប្រយោជន៍របស់ អៀង សារី នៅគ្រប់ពេលវេលា

---

[79] **CF002-E284** សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០១៣, ២៦ មេសា ២០១៣, ត្រង់ទំព័រទី៧២។

[80] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Željko Mejakić និងគូរកន*, សំណុំរឿងលេខ IT-02-65-AR73.1, សេចក្តីសំរេចលើបណ្តឹងឧទ្ធរណ៍ដោយអយ្យការ ដើម្បីដោះស្រាយលើករណីទំនាស់ផលប្រយោជន៍ទាក់ទងនឹងមេធាវីការពារក្តី Jovan Simić ( អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៤។

[81] *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី១៣។

ទាំងអស់ឲ្យដូចជាការរំពឹងចង់បានរបស់មេធាវីការពារក្ដីនៅក្នុងករណីរឿងក្ដីរបស់ *Mejakić* ដែរ។ ពួកគេគួរតែបានធ្វើយ៉ាងដូច្នេះ នៅពេលដែលពួកគេផ្ដល់ការណែនាំដល់ មាស មុត នៅក្នុងអំឡុងពេលដែលកិច្ចដំណើរការនីតិវិធីនៃការជំនុំជម្រះក្ដីប្រឆាំងនឹង អៀង សារី កំពុងតែបន្តធ្វើ ដូចជាអំពីថាតើ មាស មុត គួរតែផ្ដល់សក្ខីកម្មនៅក្នុងសំណុំរឿងលេខ០០២ ដែរឬអត់?។ ក្នុងការធ្វើដូច្នេះ គឺជាការសមហេតុសមផលដើម្បីធ្វើការសន្និដ្ឋានថា សហមេធាវីតែងតាំងអាចមិនបានផ្ដល់ដោយពេញលេញនូវការប្រឹក្សាយោបល់ផ្នែកច្បាប់ដោយឯករាជ្យដល់ មាស មុត ដើម្បីចូលរួមនៅក្នុងដំណើរការនីតិវិធីនៃសំណុំរឿងលេខ០០២នោះទេ សូម្បីតែចំពោះផលប្រយោជន៍ដើម្បីការពារប្រឆាំងនឹងការដាក់បន្ទុកលើខ្លួនឯងនៅក្នុងវិធាន២៨ នៃវិធានផ្ទៃក្នុងក៏មិនបានផ្ដល់ការប្រឹក្សាយោបល់ដែរ។ ផ្អែកលើអង្គហេតុទាំងនេះទំនាស់ផលប្រយោជន៍ពិតជាបានកើតឡើងរួចហើយមែន។ ដោយហេតុថា សំណុំរឿងលេខ០០២ កំពុងបន្តដំណើរការ និងភស្តុតាងបន្ថែមត្រូវបានគេគិតជាមុន ទុកសម្រាប់ដំណាក់កាលក្រោយៗទៀតនៃសវនាការនោះ គ្រោះថ្នាក់គឺនៅមានជាបន្ត ដែលថាចម្លើយ ឬភស្តុតាងពីមុនៗរបស់ មាស មុត អាចនឹងត្រូវបានគេប្រើប្រាស់ដើម្បីធ្វើឲ្យមានការជាប់ទាក់ទិនដល់អ្នកដឹកនាំថ្នាក់មជ្ឈិម ដែលការណ៍នេះគឺមានលក្ខណៈផ្ទុយគ្នាទៅនឹងផលប្រយោជន៍របស់ អៀង សារី។ លទ្ធភាពនេះអាចនឹងមានអត្ថិភាពទៅបាន ព្រោះថា មាស មុត អាចនឹងត្រូវបានគេអញ្ជើញឲ្យមកផ្ដល់សក្ខីកម្ម។ នៅក្នុងនាដកថាណាមួយក៏ដោយក្នុងចំណោមនាដកថាទាំងនេះ ទំនាស់ផលប្រយោជន៍របស់មេធាវីការពារក្ដីដែលធ្លាប់បានធ្វើជាតំណាងឲ្យ អៀង សារី ហើយដែលឥឡូវនេះ បានផ្ដល់ប្រឹក្សា ឬបានធ្វើជាតំណាងឲ្យ មាស មុត គឺមុខជា និងអាចមានជា បុរេវិនិច្ឆ័យ ដោយមិនអាចត្រឡប់ក្រោយបាន ទៅលើកិច្ចការរដ្ឋបាលរបស់តុលាការ ជាមិនខានឡើយ។

### (ii) *ការបោះបង់សិទ្ធិ*

៣៤-សហមេធាវីតែងតាំងបានជជែកថា ការវាយតម្លៃអំពីលក្ខណៈនិងវិសាលភាពនៃការបោះបង់សិទ្ធិណាមួយនៃទំនាស់ផលប្រយោជន៍គឺតម្រូវឲ្យពួកគេផ្សាយប្រាប់ឲ្យគេដឹងនូវព័ត៌មានសម្ងាត់ ហើយតម្រូវឲ្យ មាស មុត ត្រូវតែប្រាប់ឲ្យដឹងពីចំណុចជាក់លាក់នានានៃការប្រឹក្សាយោបល់ផ្នែកច្បាប់ដល់គាត់ ក៏ដូចជា "យុទ្ធសាស្ត្រក្នុងការការពារក្ដី" របស់គាត់[82]។ ពួកគេថែមទាំងបានចោទប្រកាន់ថាការបញ្ចេញឲ្យដឹងដោយសារការបង្ខិតបង្ខំនូវព័ត៌មានបែបនេះ គឺជាការជ្រៀតជ្រែកចូលទៅក្នុងសិទ្ធក្នុងការនៅស្ងៀម

[82] ឯកសារលេខ **D56/9** ចម្លើយតបលើកទីពីរ កំណត់សំគាល់លេខ១ *ខាងដើម* ត្រង់កថាខណ្ឌទី២៧។

មិនឆ្លើយវា មាស មុត និងសិទ្ធរបស់គាត់មិនត្រូវបានគេបង្ខិតបង្ខំឲ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង[83]។ នៅក្នុងចម្លើយតបបានបញ្ជាក់អះអាងថា ការណ៍ដែលប្រធានអង្គភាពគាំពារការការពារក្តី (DSS) បានជួបជាមួយមាស មុតជាឯកជនគឺជាការគ្រប់គ្រាន់ និងធានាឲ្យប្រាកដថា៖ (ក) តាមការពិត មាស មុត បានស្នើសុំឲ្យចាត់តាំងសហមេធាវីចាត់តាំង។ (ខ) បានអនុវត្តនូវការបោះបង់សិទ្ធិ និងការជូនដំណឹង។ និងតាមការសន្និដ្ឋាន (គ) [ដូចបានបញ្ជាក់ជូនលោកប្រធានអង្គភាពគាំពារការការពារក្តីហើយ] "អំពីកាលៈទេសៈនានាដែលក្នុងនោះការបោះបង់សិទ្ធិ និងការជូនដំណឹងត្រូវបានផ្តល់ជូន"[84]។ ពាក់ព័ន្ធនឹងការបោះបង់សិទ្ធិ ដែលបានផ្តល់ជូនដោយ អៀង សារី នោះ នៅក្នុងចម្លើយតបបានបញ្ជាក់អះអាងថាច្បាប់ដូចដែលបានបញ្ជូនមកដោយសហព្រះរាជអាជ្ញា គឺបង្កប់ន័យថា "ការបោះបង់សិទ្ធិផ្សេងៗដោយកូនក្តី នឹងត្រូវឈប់លែងមានសុពលភាពជាស្វ័យប្រវត្តិ នៅពេលបន្ទាប់ពីកូនក្តីទាំងនោះបានទទួលមរណៈភាព"[85]។

៣៥-ផ្ទុយទៅវិញ សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដោយសារតែពុំមានចំណុចជាក់លាក់នៅក្នុងការបោះបង់សិទ្ធិរបស់ មាស មុត និង អៀង សារីនោះ ត្រូវបាន[86] ពិនិត្យពិចារណាទៅលើការទំនាក់ទំនងដ៏ជិតស្និទ្ធរវាងថ្នាក់លើនិងកូនចៅក្រោមបង្គាប់របស់ពួកគេ និងទៅលើករិតនៃភាពស្មុគស្មាញនៃសំណុំរឿងលេខ០០២ និងលេខ០០៣ ហើយការចារណានេះនៅតែផ្ទើតទៅទៀតនៅឡើយ -ដែលផ្តល់នូវមូលដ្ឋានដ៏សមហេតុផលដើម្បីធ្វើការសន្និដ្ឋានថា ទាំងកូនក្តីក្តីក៏មិនបានផ្តល់ *នូវការយល់ព្រមឲ្យបានពេញលេញ និងដោយបានទទួលនូវការផ្តល់ព័ត៌មានគ្រប់ជ្រុងជ្រោយ* ចំពោះការបោះបង់សិទ្ធិរបស់គាត់នោះដែរ...។ ការបោះបង់សិទ្ធិដែលមានលក្ខណៈមិនគ្រប់គ្រាន់ដូចនេះ មិនគ្រាន់តែមានផលវិបាកផ្សេងៗយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិរបស់ជនសង្ស័យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលេចឡើងនូវគំរោងក្នុងការនៃការលើកឡើងអះអាងអំពីជំនួយដែលមិនមានប្រសិទ្ធភាព ពីសំណាក់មេធាវីការពារក្តីលើបណ្តឹងសាទុក្ខ ឬបណ្តឹងសើរើ[87]។ សហមេធាវីតែងតាំងគ្មានផ្លូវអាចនឹងជជែកតវ៉ាថា វិធានស្តីពី

---

[83] ឯកសារលេខ **D56/9** *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី២៧។

[84] ឯកសារលេខ **D56/9** *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី៥១ [មានការពិបាកក្នុងការយល់ដឹងដោយអារម្មណ៍ ចំពោះចំណុច (គ)ដែលយកមកពីក្នុងអត្ថបទនៃចម្លើយតបដែលបានដាក់ជូន]។

[85] ឯកសារលេខ **D56/9** *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី២៧។

[86] ឯកសារលេខ **D56/7** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម, កំណត់សំគាល់លេខ២ *ខាងដើម* ត្រង់កថាខណ្ឌទី ៧៩-៨០។

[87] ឯកសារលេខ **D56/7** *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី៨១។

នីតិវិធីជាតិឬអន្តរជាតិតម្រូវឲ្យមានការយល់ព្រមដោយពេញលេញ និងដោយបានទទួលព័ត៌មានគ្រប់ជ្រុងជ្រោយដើម្បីបោះបង់សិទ្ធិក្នុងទំនាស់ផលប្រយោជន៍នោះឡើយ[88]។

## V. **ឧបាស្រ័យដែលស្នើសុំ**

៣៦- អាស្រ័យហេតុដូចខាងលើនេះ សហព្រះរាជអាជ្ញាសូមស្នើដល់សហចៅក្រមស៊ើបអង្កេត សូមមេត្តា**ទទួលយក** និង **ដំកល់ទុកដដែល** នូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទាំងមូល។ សូមមេត្តា**ច្រានចោល**នូវការតែងតាំងសហមេធាវីចាត់តាំង និង**ណែនាំ** ដល់អង្គភាពគាំពារការការពារក្តី (DSS) ឲ្យជូនដំណឹងដល់ជនសង្ស័យទៅតាមនេះ ហើយសូមជួយគាត់នៅក្នុងការអនុវត្តសិទ្ធិក្នុងការទទួលបាននូវមេធាវីការពារក្តីអាស្រ័យទៅតាមការចាំបាច់។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៣ | **លោក** William SMITH<br>សហព្រះរាជអាជ្ញារង | ភ្នំពេញ | |

[88] ឯកសារលេខ **D56/1** សំណើ កំណត់សំគាល់លេខ៣ *ខាងដើម* ត្រង់កថាខណ្ឌទី២២ និងទី៣៣-៣៤។